## ការពង្រឹងក្រុមជំនុំរបស់លោកអ្នក

# ឲ្យក្លាយជាក្រុមជំនុំមួយ ដែលមានឥទ្ធិពល!

## សេចក្ដីណែនាំសម្រាប់អ្នកដឹកនាំសិក្ខាសាលា

### សេចក្ដីអត្ថាធិប្បាយ

ការពង្រឹងឲ្យមានសិក្ខាសាលាក្នុងក្រុមជំនុំរបស់លោកអ្នក ជួយអ្នកដឹកនាំក្រុមជុំនុំលោកអ្នកឲ្យមានសមត្ថភាពនៅតែផ្តោតទៅលើកិច្ចការរបស់ខ្លួន ក្នុងនាមជាភ្នាក់ងាររបស់ព្រះ នៅកន្លែងដ៏ជាក់លាក់ណាមួយ។ សិក្ខាសាលានេះ បង្ហាញជូនពីសារសំខាន់នៃនិមិត្ត ដែលបានរកឃើញនៅក្នុងព្រះគម្ពីរ ណែនាំអ្នកដឹកនាំឲ្យស្គាល់ចរិតលក្ខណៈទាំងដប់របស់ក្រុមជំនុំដែលមានសុខភាពល្អ ហើយអញ្ជើញអ្នកដឹកនាំឲ្យមើលឃើញក្រុមជុំនុំរបស់ខ្លួន ថាជាប្រព័ន្ធមួយ ដែលអាចមានឥទ្ធិពលដ៏សំខាន់លើសហគមន៍របស់ខ្លួន។

multiplication network

*more churches, stronger churches*

**មគ្គុទ្ទេសក៍របស់អ្នកដឹកនាំ|**

គោលបំណងរបស់ THE MULTIPLICATION NETWORK

ការដាំក្រុមជំនុំដែលមានសុខភាពល្អ ជាវគ្គសិក្ខាសាលាផ្អែកលើទៅលើសៀវភៅមួយដែលមានចំណងជើងតែមួយ និងត្រូវបានសរសេរនៅអាមេរិក ដោយអ្នកនិពន្ធចំនួនម្ភៃពីរូបមកពីដប់មួយប្រទេស។

នៅក្នុងសៀវភៅនេះ មានសំណួរឆ្លុះបញ្ចាំង និងសកម្មភាព។ សំណួរ និងសកម្មភាពទាំងនេះ អាចត្រូវបានធ្វើឡើងជាលក្ខណៈផ្ទាល់ខ្លួន ជាដៃគូ ឬជាក្រុមតូច។ សូមរើសសំណួរ និងសកម្មភាពស័ក្តិសមបំផុតសម្រាប់សិក្ខាកាមរបស់លោកអ្នក ដើម្បីប្រើក្នុងពេលធ្វើសិក្ខាសាលា និងត្រូវសុំសិក្ខាកាម ឲ្យត្រឡប់ទៅកាន់សំណួរមួយទៀតដោយខ្លួនឯង បន្ទាប់ពីចប់សិក្ខាសាលា។

ប្រសិនបើលោកអ្នកត្រូវការជំនួយសម្រាប់សិក្ខាសាលា សូមទាក់ទងតំណាង THE MULTIPLICATION NETWORK នៅក្នុងប្រទេសរបស់លោកអ្នក។ អាសយដ្ឋានទំនាក់ទំនងរបស់ពួកគេ អាចរកបាននៅលើគេហទំព័ររបស់យើង។

មេរៀនដែលអ្នកដឹកនាំសិក្ខាសាលាត្រូវមានៈ

១, សៀវភៅមេរៀនរបស់អ្នកដឹកនាំ

២, សៀវភៅមេរៀនរបស់សិក្ខាកាម

៣, ការបញ្ចាំងរូបភាពពណ៌ ឬ PowerPoint slides (អាចរកបានលើ CD ឬតាមរយៈគេហទំព័ររបស់យើង)

៤, ជំនួយមកពីគ្រូហ្វឹកហ្វឺន MNM (ចូលទៅកាន់គេហទំព័ររបស់យើង www.multiplicationnetwork.org

ព័ន្ធកិច្ច The Multiplication Network ជួយឲ្យមានការរីកចម្រើន និងការដាំក្រុមជំនុំ តាមរយៈការហ្វឹកហ្វឺនគ្រូគង្វាល និងអ្នកដឹកនាំ។ លោកអ្នកអាចរកបានមេរៀនរបស់យើងឥតគិតថ្លៃ ដោយទាញយកពី Internet ហើយ Print ចេញយកទៅប្រើប្រាស់ ដោយចូលទៅក្នុងគេហទំព័ររបស់យើង www.multiplicationnetwork.or

**របៀបប្រើមគ្គុទ្ទេសក៍នេះ|**

មគ្គុទ្ទេសក៍របស់គ្រូនេះ នឹងបង្ហាញលោកអ្នកមួយទំព័រម្តងៗ អំពីរបៀបដឹកនាំសិក្ខាសាលានេះ។ ជាការសំខាន់ណាស់ ដែលត្រូវចាំថា គ្រូហ្វឹកហ្វឺនម្នាក់ៗមានសេរីភាពនឹងបន្ថែមមេរៀន ដែលផ្អែកទៅលើបទពិសោធន៍របស់ពួកគេ ការប្រើប្រាស់រូបភាពពន្យល់ និងរឿងខ្លីៗរបស់ខ្លួន។ នៅខាងឆ្វេងនៃទំព័រនីមួយៗ លោកអ្នកនឹងឃើញយោបល់សម្រាប់គ្រូហ្វឹកហ្វឺន និង PowerPoint slides ដែលប្រើសម្រាប់ទំព័រនោះ។ ផ្នែកដ៏សំខាន់នៃទំព័រនីមួយៗ មានទំព័រដូចបានបង្ហាញនៅក្នុងផ្ទាំងកម្រងឯកសារមេរៀន រួមមានទាំងចម្លើយសម្រាប់គ្រូហ្វឹកហ្វឺនផងដែរ។ ប្រហែលជាគ្មានពេលគ្រប់គ្រាន់សម្រាប់សកម្មភាពឆ្លុះបញ្ចាំង រួមទាំងសៀវភៅមេរៀនទាំងអស់នោះទេ។ សូមប្រើប្រាស់មេរៀនណាមួយដែលស័ក្តិសមបំផុតទៅនឹងក្រុមរបស់លោកអ្នក រួចលើកទឹកចិត្តសិក្ខាកាមឲ្យធ្វើមេរៀនមួយទៀត ដោយខ្លួនឯង បន្ទាប់ពីវគ្គហ្វឹកហ្វឺននេះ។

**កាលវិភាគដាក់ជូន|**

យើងបានដាក់ជូនកាលវិភាគ សម្រាប់សិក្ខាសាលារយៈពេលមួយថ្ងៃ។ ទោះជាយ៉ាងណាក្តី យើងសូមលើកទឹកចិត្តឲ្យលោកអ្នករៀបចំកាលវិភាគទៅតាមអ្វីដែលប្រសើរបំផុតសម្រាប់លោកអ្នក និងសិក្ខាកាម។ លោកអ្នកក៏អាចធ្វើសិក្ខាសាលារយៈពេលបួនសប្តាហ៍ (មួយសប្តាហ៍មួយវគ្គ) ឬនៅរាល់ព្រឹកថ្ងៃសុក្រ និងថ្ងៃសៅរ៍ ដើម្បីកាត់បន្ថយចំណាយ។ វគ្គនីមួយៗត្រូវបានគេរៀបចំសម្រាប់រយៈពេលមួយម៉ោងកន្លះ។ សូមលៃពេលល្មមឲ្យសិក្ខាកាមបំពេញក្រដាសវាយតម្លៃបាន។ ប្រសិនបើអាច សូមថតរូប digital សិក្ខាសាលារបស់លោកអ្នកមួយសន្លឹកផ្ញើមកកាន់ Multiplication Network រួមជាមួយរបាយការណ៍របស់លោកអ្នកអំពីព្រឹត្តិការណ៍នោះ (សូមចូលទៅកាន់គេហទំព័ររបស់យើងដើម្បីរកគំរូរបាយការណ៍ ឬនៅទំព័រទី៩១ នៃសៀវភៅមេរៀននេះ សម្រាប់ព័ត៌មានដែលយើងចង់ឲ្យលោកអ្នកផ្ញើមកយើង)។

**មេរៀនសិក្ខាសាលា|**

គោលបំណងរបស់យើង គឺឲ្យសិក្ខាសាលានេះអាចធ្វើបានសម្រាប់អ្នកដឹកនាំ ឲ្យបានច្រើនតាមដែលអាចធ្វើបាន ដោយចំណាយថវិកាតិចតួច ឬអាចមិនចំណាយសោះ។ លោកអ្នកអាចថតចម្លងនៅក្នុងស្រុក ចំពោះសៀវភៅមេរៀនរបស់សិក្ខាកាម ហើយសហការណ៍ជាមួយក្រុមជំនុំដែលពាក់ព័ន្ធ ក្នុងការរៀបចំភេសជ្ជៈ និងអាហារផ្សេងៗ។ លោកអ្នកអាចធ្វើក្របផ្សេងពីនេះដោយសេរី ជាមួយនឹងការតុបតែងរចនាឲ្យកាន់តែស័ក្តិសមទៅនឹងបរិបទ នៅក្នុងសៀវភៅមេរៀនដែលត្រូវប្រើនេះ។

MULTIPLICATION NETWORK

ខគម្ពីរយោងទាំងអស់បានមកពីសំណៅគម្ពីរ New International Version រក្សាសិទ្ធិ 1973, 1978, 1984 ។

**មាតិកា**

មេរៀនទី១|

ចិត្តឆេះឆួល និមិត្ត បេសកកម្ម ....................................................3

មេរៀនទី២|

កត្តាផ្សឹទាំងប្រាំនៃក្រុមជំនុំដែលមានសុខភាពល្អ................................7

មេរៀនទី៣|

កិច្ចការទាំងប្រាំនៃក្រុមជំនុំដែលមានសុខភាពល្អ...............................15

មេរៀនទី៤ |

ប្រព័ន្ធផ្លាស់ប្រែ .................................................................23

សេចក្តីបន្ថែម |

គ្រឹះខាងទេវសាស្ត្រ.............................................................31

បែបបទវាយតម្លៃ .................................................................33

វិញ្ញាបនប័ត្រ.....................................................................34

| **កាលវិភាគគំរូ** | |
|---|---|
| ចុះឈ្មោះ និងស្វាគមន៍ | |
| **ម៉ោងថ្វាយបង្គំ** | ៣០ នាទី |
| **វគ្គ១** | ៩០ នាទី |
| **វគ្គ២** | ៩០ នាទី |
| សម្រាកខ្លី | |
| **វគ្គ៣** | ៩០ នាទី |
| **វគ្គ៤** | ៩០ នាទី |
| វគ្គសំណួរចម្លើយ ការវាយតម្លៃ បិទវគ្គ | |

មេរៀនទី១|

# ចិត្តឆេះឆួល និមិត្ត បេសកកម្ម




### អ្វីទៅជា «ការលូតលាស់ទាំងស្រុងរបស់ក្រុមជំនុំ»?

ការលូតលាស់របស់ក្រុមជុំនុំ នឹងមានសុខភាពល្អ នៅពេលបង្កើនការកែលម្អគ្រប់ផ្នែកទាំងអស់នៃជីវិតក្រុមជំនុំ ជាជាងការដែលកើនឡើងតែចំនួនសមាជិក ឬអ្នកចូលរួម។ ក្រុមជុំនុំដែលមានសុខភាពល្អ មើលឃើញខ្លួនឯងថាស្ថិតនៅក្នុងគម្រោងព្រះហឫទ័យរបស់ព្រះ សម្រាប់ពិភពលោក សម្រាប់មនុស្សជាតិ និងអ្វីៗសព្វសារពើ គឺថា ធ្វើឲ្យអ្វីៗទាំងអស់ក្នុងជីវិត មានការកែជាថ្មី។ ក្រុមជុំនុំ យកព្រះរាជ្យរបស់ព្រះជាចំណុចចាប់ផ្ដើម ហើយស្វះស្វែងពង្រីកព្រះរាជ្យរបស់ព្រះក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិត (គ្រួសារ សហគមន៍ ការងារ ។ល។) តាមរយៈព្រះចេស្ដានៃដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្ត។

## គម្រោងសម្រាប់ការលូតលាស់ទាំងស្រុងរបស់ក្រុមជំនុំ

មេរៀននេះជួយយើងឲ្យចាំថា ទំនាក់ទំនងថ្វាយបង្គំផ្ទាល់ខ្លួនមានសារសំខាន់ណាស់ ដើម្បីសម្រេចកិច្ចការដែលព្រះអង្គត្រាស់ហៅយើងឲ្យធ្វើ។ ពេលយើងមានចិត្តឆេះឆួលសម្រាប់កិច្ចការរបស់ព្រះ នោះយើងនឹងទទួលបាននិមិត្តមួយ អំពីអ្វីដែលព្រះចង់ឲ្យយើងធ្វើ ហើយព្រះអង្គអាចធ្វើតាមរយៈយើង។ ពេលយើងឆ្លើយតបដោយការស្ដាប់បង្គាប់ចំពោះការត្រាស់ហៅរបស់ព្រះ ក្រុមជុំនុំនឹងលោតចូលទៅក្នុងបេសកកម្មសម្រាប់ពិភពលោក។ ការនេះកើតឡើងបាន តែនៅពេលដែលយើងយល់អ្វីៗដែលព្រះគម្ពីរបង្រៀនយើង អំពីទំនាក់ទំងរវាងព្រះ ក្រុមជុំនុំ និងសហមគមន៍។

**លំហាត់** | គូសចំណុចភ្ជាប់គ្នា



សូមព្យាយាមគូសភ្ជាប់ចំណុចទាំងអស់ ដោយគូសបន្ទាត់បួន ដោយមិនដកដៃខ្មៅចេញ។

មនុស្សតែងភ្ញាក់ផ្អើល ដោយឃើញថា ដើម្បីដោះស្រាយបញ្ហា គេត្រូវគូសបន្ទាត់ទៅឲ្យហួសពីចំណុចដៅ។ ជាច្រើនដង យើងត្រូវពង្រីករបៀបនៃការគិតរបស់យើង គឺ «គិតក្រៅប្រអប់» ដើម្បីឲ្យមានចិត្តស្មោះត្រង់ចំពោះព្រះ។ ជាការសំខាន់ណាស់ ដែលត្រូវដឹងថា យើងទាំងអស់គ្នាសុទ្ធតែមាន «ចំណុចដៅ» ខាងគំនិត និងទស្សនៈនៃព័ន្ធកិច្ច ដែលអាចរាំងរាយើងពីភាពស្មោះត្រង់ចំពោះបេសកកម្មរបស់យើង និងពីការមើលឃើញពីលទ្ធផលដ៏ប្រសើរដែលកើតចេញពីបេសកកម្មរបស់យើង។

មេរៀននេះចាប់ផ្ដើមដោយការពន្យល់អំពីការលូតលាស់របស់ក្រុមដែលមានសុខភាពល្អ។

**«នំប៉័ងនៅម្ខាង ទឹកដោះគោនៅម្ខាង»** | ពន្យល់អំពីសារសំខាន់នៃការអនុវត្តន៍ទ្រឹស្ដីអំពីការលូតលាស់របស់ក្រុមជំនុំ និងយុទ្ធសាស្ត្រសម្រាប់បរិបទ។

ច្រើនឆ្នាំកន្លងមកនេះ ហាងលក់គ្រឿងទេសជាច្រើននៅសហរដ្ឋអាមេរិក បានរកឃើញយុទ្ធសាស្ត្រមួយ ឲ្យអតិថិជនទិញកាន់តែច្រើន។ អតិថិជនមកហាងដើម្បីទិញទំនិញសំខាន់ៗ ដូចជានំប៉័ង និងទឹកដោះគោ ប៉ុន្តែ គេនឹងទិញថែមទៀត ប្រសិនបើគេបានដើរកាត់ទំនិញផ្សេងទៀត ដែលមានស្លាកដាក់ថា ផ្ដល់ជូនតម្លៃពិសេស។ សព្វថ្ងៃនេះ ហាងជាច្រើនធ្វើការសិក្សាគ្រប់បែបយ៉ាង ដើម្បីស្វែងរកមធ្យោបាយ ធ្វើឲ្យអតិថិជនទិញកាន់តែច្រើន នៅពេលដែលពួកគេទិញទំនិញ ចេញពីចង្វាក់តន្ត្រីដែលគេប្រគុំ (តន្ត្រីកាន់តែយឺត មនុស្សដើរកាន់តែយឺត) ឆ្ពោះទៅផ្លូវដែលពួកគេដាក់ទំនិញ (ដាក់ទំនិញដែលពួកគេចង់លក់បំផុត ឬ អាចនឹងទាក់ភ្នែកអតិថិជន)។

ប្រសិនបើហាងជាច្រើនចំណាយពេលច្រើនបំផុត ដើម្បីសិក្សាពីរបៀបដែលមនុស្សទិញឥវ៉ាន់ ដើម្បីឲ្យពួកគេលក់ទំនិញបានកាន់តែច្រើន តើយើងជាគ្រិស្តបរិស័ទ មិនគួររៀនឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន អំពីមនុស្ស និងរបៀបដែលពួកគេប្រព្រឹត្ត ដើម្បីអាចអញ្ជើញពួកគេ យ៉ាងមានប្រសិទ្ធភាពឲ្យមកស្គាល់ព្រះគ្រិស្ត និងក្លាយជាប្រជារាស្ត្ររបស់ព្រះអង្គទេឬ? ទោះបីរាជសារសំខាន់អំពីជីវិតនៅក្នុងព្រះគ្រិស្ត មិនដែលប្រែប្រួល ប៉ុន្តែ វប្បធម៌ និងរបៀបដែលមនុស្សធ្វើការ តែងប្រែប្រួលជានិច្ច។ ដូច្នេះ វិធីសាស្ត្រ និងយុទ្ធសាស្ត្ររបស់យើង សម្រាប់ការចែកចាយប្រាប់ដំណឹងល្អ ក៏ត្រូវតែប្រែប្រួលឲ្យត្រូវទៅតាមបរិបទ ដែលយើងកំពុងចែកចាយប្រាប់អំពីព្រះគ្រិស្តយ៉ាងនោះដែរ។

**និមិត្ត** | គោលដៅចម្បង គឺដើម្បីឲ្យអ្នកដឹកនាំយល់ អំពីសារសំខាន់ នៃការមាននិមិត្តដែលជំរុញចិត្ត ច្បាស់ និងមានមូលដ្ឋានតាមព្រះគម្ពីរ ដែលជំរុញអ្នកផ្សេងទៀតឲ្យរួមចំណែកជាមួយព្រះ នៅក្នុងអ្វីដែលគាត់កំពុងធ្វើ ក្នុងតំបន់របស់ខ្លួន។

**តួនាទីវ៉ែនតាម៉្វប** | អ្នកត្រូវការវ៉ែនតា ពេលពាក់វ៉ែនតាដំបូង គាត់ភ្ញាក់ផ្អើលណាស់ ទាំងដឹងថា គាត់អាចមើលឃើញច្បាស់! ព្រះគម្ពីរមានមុខងារស្រដៀងគ្នានឹងវ៉ែនតាម៉្វបដែរ។ នៅពេលដែលយើងមើលឃើញអ្វីតាមរយៈបទគម្ពីរ (ខ្លួនយើង ជីវិតយើង ស្ថានភាពយើង និងអ្នកជិតខាងយើង) គឺយើងមើលឃើញកាន់តែច្បាស់។ យើងចាប់ផ្តើមមានគំនិតរបស់ព្រះ លើជីវិតរបស់យើង និងសហគមន៍របស់យើង។

**គំរូនៅក្នុងព្រះគម្ពីរ** | ក្រុមជំនុំដែលគ្មាននិមិត្តត្រូវទៅតាមព្រះគម្ពីរ ងាយនឹងក្លាយជាបនសង្គម ជាទីភ្នាក់ងារបម្រើសេវាសហគមន៍ ឬជា «ភោជនីយដ្ឋានអាហាររហ័ស» ជាកន្លែងដែលយើងមកយកអ្វីដែលយើងចង់បាន។ ផ្ទុយទៅវិញ ត្រូវតែស្មោះត្រង់ចំពោះព្រះ យើងត្រូវរៀបចំជីវិតរបស់យើង ក្នុងនាមជាក្រុមជំនុំមួយ ដោយសារ សេចក្តីដែលព្រះមានបន្ទូលអំពីយើង។ យើងត្រូវសម្លឹងមកកាន់ក្រុមជំនុំរបស់យើង និងសហគមន៍របស់យើងដោយភ្នែករបស់ព្រះ។ តើព្រះត្រាស់ហៅយើងជាអ្វី ហើយធ្វើអ្វី?

**គំរូជាងសំណង់** | ពេលមួយ មានបុរសម្នាក់បានចូលទៅជិតបុរសបីនាក់ ដែលកំពុងកាត់ថ្ម ហើយបានសួរទៅអ្នកទាំងបីនោះថាកំពុងធ្វើអ្វី។ អ្នកទីមួយឆ្លើយថា៖ «ចិញ្ចឹមជីវិត» អ្នកទីពីរថា៖ «កំពុងធ្វើការរបស់ខ្ញុំ ក្នុងនាមជាអ្នកកាត់ថ្ម» ទីបីឆ្លើយថា៖ «កំពុងសង់វិមានដ៏ប្រណិតមួយដែលមិនធ្លាប់ឃើញមាន នៅក្នុងទីក្រុងនេះ»។ ដូចគ្នាដែរ ជាញឹកញាប់ នៅក្នុងក្រុមជំនុំ យើងទៅបំពេញការងាររបស់យើង ដោយគ្រាន់តែគិតអំពីការងារនៅពេលនោះ ដូចជា រៀបចំមេរៀនថ្នាក់ថ្ងៃអាទិត្យ យកអាហារទៅឲ្យគ្រួសារមួយដែលត្រូវការ ដាក់លុយទៅក្នុងថង់តង្វាយ ដោយមិនបានឃើញនិមិត្តធំជាង ដែលព្រះមានសម្រាប់ការងាររបស់យើង ដូចជា ជីវិត គ្រួសារ និងសហគមន៍ ដែលបានផ្លាស់ប្រែដោយសារដំណឹងល្អអំពីព្រះយេស៊ូគ្រិស្តសោះ។

## និមិត្ត

ការមាននិមិត្ត ជាការមើលឆ្ពោះទៅ **<u>អនាគត</u>** និងឃើញអ្វីដែលព្រះជាម្ចាស់ចង់ធ្វើតាមរយៈលោកអ្នក ដើម្បីសម្រេចគោលបំណងប្រោសលោះរបស់ព្រះអង្គ។

- **តួនាទីវ៉ែនតាម៉្វប**
- **គំរូក្នុងព្រះគម្ពីរ:** បទគម្ពីរមានគំរូជាច្រើនអំពីអ្នកដឹកនាំ ដែលមាននិមិត្តសម្រាប់អ្វីដែលព្រះចង់ធ្វើនៅក្នុងពួកគេ និងធ្វើតាមរយៈពួកគេ។
  ១ **លោកអ័ប្រាហាំ** មានកូនចៅជាច្រើន មានទឹកដីមួយសម្រាប់កូនចៅទាំងនោះ ហើយធ្វើជាព្រះពរដល់មនុស្សលោក: លោកុប្បត្តិ ១២:១-២។
  ២ **លោកណូអេ** រក្សារក្រុមគ្រួសារ និងពពួកសត្វឲ្យមានសុវត្ថិភាពក្នុងពេលទឹកជំនន់: លោកុប្បត្តិ ៦:១៣-១៤, ១៧-២០។
  ៣ **លោកយ៉ូស្វេ** និង**លោកកាលែប** ចូលទឹកដីដែលព្រះបានសន្យានឹងអ៊ីស្រាអែល: ជនគណនា ១៤:៦-៩។
  ៤ **លោកប៉ូល** ប្រកាសដំណឹងល្អដល់សាសន៍ដទៃ ពេញចក្រភពរ៉ូម: កិច្ចការ ២៦:១៣-១៨។
  ៥ **ព្រះយេស៊ូ** នាំការប្រោសឲ្យជា នាំសេចក្តីសង្ឃឹម និងសេរីភាព: លូកា ៤:១៨-១៩។
- ក្រុមជំនុំដែលមានសុខភាពល្អ ចាប់ផ្តើមដោយនិមិត្តដែលច្បាស់ និងជំរុញចិត្ត។
- គំរូអំពីជាងសំណង់។

**តើលោកអ្នកចង់មានចំណែកសង់ព្រះរាជ្យរបស់ព្រះឬទេ? តើនឹងចាក់គ្រឹះដំបូងនៅពេលណា?**

> តែបើឥតមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់។ ហេព្រើរ ១១:៦
>
> នៅក្នុងចិត្តមនុស្ស តែងមានគំនិតគិតធ្វើជាច្រើនយ៉ាង មានតែដំបូន្មាននៃព្រះយេហូវ៉ាប៉ុណ្ណោះ ដែលនឹងស្ថិតស្ថេរនៅ។ សុភាសិត ១៩:២១

**ដ្យាក្រាម | ទំនាក់ទំនងរវាងព្រះ - ក្រុមជំនុំ - សហគមន៍**




មេរៀននេះពណ៌នាអំពីទំនាក់ទំនងរវាងព្រះ ក្រុមជំនុំ និងសហគមន៍ទៅតាមលំដាប់សំខាន់ៗ។ ពេលដែលលោកអ្នកដឹកនាំសិក្ខាកាមឆ្លងកាត់មេរៀននីមួយៗ សូមប្រើគំរូ ឬរឿងខ្លីៗ ចេញពីព័ន្ធកិច្ចរបស់លោកអ្នកផ្ទាល់ ដើម្បីពន្យល់បង្ហាញពីចំណុចនីមួយៗ។

សូមឲ្យសិក្ខាកាមអានខសំខាន់ ដែលទាក់ទងទៅនឹងទំនាក់ទំនងរបស់ក្រុមជំនុំ ចំពោះព្រះ។ ទំនាក់ទំនងនេះជាកូនសោសម្រាប់ក្រុមជំនុំអាចរក្សាបាននូវអត្តសញ្ញាណរបស់ខ្លួន និមិត្ត និងចិត្តឆេះឆួល។ ជីវិតរបស់យើងមកពីព្រះ។ ដរាបណាយើងមិនពឹងអាងព្រះអង្គ យើងមិនអាចសម្រេចបេសកកម្មរបស់យើងបានឡើយ។ អ្នកប្រកាសដំណឹងល្អ គ្រូគង្វាល និងអ្នកដាំក្រុមជំនុំដ៏ល្បីៗ គេមានជោគជ័យ ដោយសារគេមានទំនាក់ទំនងជាមួយព្រះ។ ការចំណាយជាមួយព្រះ តាមរយៈការអធិស្ឋាន និងការសញ្ជឹងគិតបទគម្ពីរ មានប្រយោជន៍ឲ្យយើងស្គាល់ព្រះ ស្គាល់ព្រះហឫទ័យព្រះអង្គ ហើយមានកម្លាំងបម្រើព្រះអង្គ។

ដ្យាក្រាមនេះបង្ហាញអំពីទំនាក់ទំនងបីនៅក្នុងរូបភាពតែមួយ។

## ១ ទំនាក់ទំនងរវាងក្រុមជំនុំ និងព្រះ

**គោលការណ៍** | ដើម្បីឲ្យក្រុមជំនុំណាមួយមានឥទ្ធិពលលើសហគមន៍របស់ខ្លួន គ្មានអ្វីក្រៅពីមានទំនាក់ទំនងដ៏ជ្រាលជ្រៅជាប់ជានិច្ចជាមួយព្រះអម្ចាស់ឡើយ។

> *«ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ»* យ៉ូហាន ១៥:៥។
>
> *«បើគ្មានព្រះយេហូវ៉ាសង់ផ្ទះឡើង នោះពួកជាងដែលសង់ គេធ្វើការជាឥតប្រយោជន៍ទេ»* ទំនុកតម្កើង ១២៧:១។

## ២ ទំនាក់ទំនងរវាងព្រះ និងសហគមន៍

**គោលការណ៍** | គំរូអំពីការយាងមកកើតជាមនុស្សរបស់ព្រះយេស៊ូ ភីលីព ២:៥-៨: ព្រះតែងធ្វើការនៅក្បែរយើងជានិច្ច។ ព្រះអង្គគង់នៅកន្លែងមួយ តាំងពីយូរ មុនពេលអ្នកប្រកាសដំណឹងល្អដំបូង ឬបេសកជនដំបូងទៅដល់ទីនោះទៅទៀត។

> *«ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»* យ៉ូហាន ៣:១៦។
>
> *«ព្រះយេស៊ូវ ទ្រង់ក៏យាងទៅដល់គ្រប់ក្រុងគ្រប់ភូមិ ព្រមទាំងបង្រៀនក្នុងសាលាប្រជុំទាំងប៉ុន្មាន ហើយប្រកាសប្រាប់ដំណឹងល្អពីនគរ ទ្រង់ក៏ប្រោសអស់ទាំងជំងឺរោគា និងជរាពិការ ក្នុងពួកបណ្តាជនឲ្យបានជា»* ម៉ាថាយ ៩:៣៥។
>
> *«កាលទ្រង់ឃើញហ្វូងមនុស្សហើយ នោះទ្រង់មានព្រះហឫទ័យក្តួលអាណិត...»* ម៉ាថាយ ៩:៣៦។

## ៣ ទំនាក់ទំនងរវាងក្រុមជំនុំ និងសហគមន៍

**គោលការណ៍** | ព្រះចង់ធ្វើការតាមរយៈយើង។ យើងជាដៃជាជើងរបស់ព្រះអង្គ និងជាសំឡេងរបស់ព្រះអង្គនៅក្នុងពិភពលោកនេះ។ មុនពេលសម្រេចការធំ យើងត្រូវស្មោះត្រង់នឹងការតូច។

> ទូលបង្គំបានចាត់គេឲ្យទៅក្នុងលោកីយ៍ ដូចជាទ្រង់ចាត់ទូលបង្គំ ឲ្យមកក្នុងលោកីយ៍ដែរ (យ៉ូហាន ១៧:១៨)

សូមអានខគម្ពីរ ដែលនិយាយអំពីទំនាក់ទំនងរវាងព្រះ និងសហគមន៍។ ព្រះទ្រង់គិតដល់មនុស្សបាត់បង់។ នៅក្នុងព័ន្ធកិច្ចរបស់ព្រះយេស៊ូ ព្រះអង្គបានយាងទៅរកអ្នកបាត់បង់ អ្នកជំងឺ និងមនុស្សដែលគេលែងរាប់រក ដើម្បីប្រោសគេឲ្យបានជា និងស្រោចស្រង់គេឲ្យបានរួច។ ព្រះជាម្ចាស់ក៏ធ្វើការនៅក្នុងចិត្តមនុស្ស និងនៅក្នុងសហគមន៍ដែរ មុនពេលយើងទៅដល់ទីនោះ។ ព្រះអង្គត្រាស់ហៅយើងឲ្យចូលរួមចំណែកនៅក្នុងអ្វីដែលព្រះអង្គកំពុងធ្វើ និងធ្វើការតាមរយៈយើង នៅពេលដែលយើងទៅប្រកាសដំណឹងល្អ ឲ្យអ្នកទាំងនោះជឿ។

ចុងក្រោយ សូមអានខគម្ពីរដែលទាក់ទងទៅនឹងទំនាក់ទំនងរវាងក្រុមជំនុំ និងសហគមន៍។ ព្រះជាម្ចាស់ត្រាស់ហៅយើងធ្វើជាដៃជើងរបស់ព្រះអង្គ និងជាសំឡេងរបស់ព្រះអង្គ នៅក្នុងសហគមន៍ដែលព្រះអង្គបានដាក់យើងនៅទីនោះ។ សូមឲ្យអ្នកណាម្នាក់ លើកឧទាហរណ៍អំពីក្រុមជំនុំមួយ ដែលគេដឹងថា ក្រុមជំនុំនោះមានទំនាក់ទំនងជាមួយព្រះ ហើយជាដៃជើងរបស់ព្រះអង្គ នៅក្នុងសហគមន៍របស់គេ។

**រឿងរបស់នាងផ្លរិនស៍ ឆាដវិក** | នៅព្រឹកថ្ងៃទី4 កក្កដា 1952 នាងផ្លរិនស៍ ឆាដវិក បានលោតចូលទៅក្នុងទឹកត្រជាក់នៅកោះ កាថាលីណា ដោយមានបំណងហែលទៅកាន់ឆ្នេរកាលីហ្វូញ៉ា ដែលមានចម្ងាយ 35 គម។ នាងបានឆ្លងកាត់ស្ទឹង ទន្លេ បឹងផ្សេងៗជាច្រើនរួចមកហើយ ប៉ុន្តែ ថ្ងៃនេះ អ្វីៗដូចជាប្លែក។ ទឹកត្រជាក់ និងមានអព្ភ ធ្វើឲ្យនាងមើលមិនបានឆ្ងាយ។ ក្រោយពីបានហែលអស់15ម៉ោង នាងបានអស់កម្លាំង ហើយបានសុំឲ្យមនុស្សដែលតាមពីក្រោយនាង លើកនាងឡើងទូក។ ម្តាយ និងគ្រូបង្វឹករបស់នាង បានព្យាយាមឲ្យនាងបន្តទៅមុខទៀត ប៉ុន្តែពីរបីនាទីក្រោយមក នាងបានបោះបង់ចោល មិនអាចទៅដល់គោលដៅ។ នៅពេលដែលទូកទៅដល់ច្រាំង នាងដឹងថា នាងហែលបានតែ700ម ពីច្រាំងប៉ុណ្ណោះ នៅពេលដែលនាងសុំឈប់។ គួរឲ្យស្តាយ។ នាងផ្លរិនស៍បានពន្យល់ថា ប្រសិនបើនាងអាចមើលឃើញឆ្នេរច្បាស់ នាងនឹងធ្វើឲ្យបានសម្រេច ទោះបីជាទឹកត្រជាក់ និងអស់កម្លាំងក៏ដោយ ប៉ុន្តែ អព្ភធ្វើឲ្យនាងមើលមិនឃើញឆ្នេរ។ ប៉ុន្មានខែក្រោយមក ផ្លរិនស៍បានត្រឡប់ទៅកាន់កោះកាថាលីណា ហើយមានបំណងហែលឆ្លងម្តងទៀត។ ទឹកត្រជាក់ និងមានអព្ភចុះដូចមុន ឬលើសមុនទៅទៀត ប៉ុន្តែ នាងបានហែល រហូតមកដល់ឆ្នេរកាលីហ្វូញ៉ា។ ពេលដែលគេសួរថា ម្តេចបានជានាងអាចធ្វើបាន នាងឆ្លើយថា៖ «លើកនេះ ឆ្នេរនៅក្នុងចិត្តខ្ញុំរួចហើយ»។

*សំណួរសម្រាប់យើងជាអ្នកដឹកនាំគ្រិស្តបរិស័ទ គឺដូចគ្នា។ តើយើងមាននិមិត្តរបស់ព្រះ សម្រាប់សហគមន៍របស់យើង នៅក្នុងចិត្តរបស់យើងឬទេ? តើយើងត្រៀមប្រយុទ្ធនឹងព្យុះភ្លៀង ដើម្បីសម្រេចគោលបំណង ដែលព្រះមានសម្រាប់យើងឬទេ?*

*«ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំ ឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ និងសេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយឲ្យដោះមនុស្ស ដែលត្រូវគេជិះជាន់ឲ្យរួច ព្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះអម្ចាស់កំណត់ទុក»* លូកា ៤:១៨-១៩។

*«ចៅហ្វាយនិយាយថា ប្រពៃហើយ បាវល្អស្មោះត្រង់អើយ ឯងមានចិត្តស្មោះនឹងត្រួតរបស់បន្តិចនេះ ដូច្នេះ អញនឹងតាំងឲ្យឯងត្រួតលើរបស់ជាច្រើនទៅទៀត ចូរឲ្យឯងប្រកបដោយសេចក្តីអំណររបស់ចៅហ្វាយឯងចុះ»* ម៉ាថាយ ២៥:២១។

**ដ្យាក្រាម | ចិត្តឆេះឆួល - និមិត្ត - បេសកកម្ម**

គំនិតនេះពណ៌នាអំពីគំនិត ដោយមានដ្យាក្រាមសង្ខេបអំពីបេសកកម្មក្រុមជំនុំ។ ដ្យាក្រាមត្រូវបានពន្យល់តាមរបៀបខាងក្រោមនេះ:




១ ដោយសារមានទំនាក់ទំនងជាមួយព្រះ ក្រុមជំនុំមាន**ចិត្តឆេះឆួល**បម្រើព្រះអង្គ។ សហគមន៍មើលឃើញចិត្តឆេះឆួល តាមរយៈសកម្មភាព ដែលដើរតួជា**ទីបន្ទាល់**របស់ក្រុមជំនុំ។

២ ព្រះធ្វើការនៅក្នុងសហគមន៍ ហើយក្រុមជំនុំចាប់យក**និមិត្ត**នេះបាន នៅពេលគេយល់អ្វីដែលព្រះកំពុងធ្វើ នៅក្នុងពិភពលោកនេះ។ ការនេះផ្តល់ឲ្យក្រុមជំនុំដឹង**គោលបំណង**។

៣ ព្រះជាម្ចាស់ចាត់ក្រុមជំនុំឲ្យបំពេញ**បេសកកម្ម**នៅក្នុងសហគមន៍របស់ខ្លួន ហើយព្រះអង្គបានបន្ថែម**ព្រះពរ**របស់ព្រះអង្គ នៅពេលដែលក្រុមជំនុំស្តាប់បង្គាប់ព្រះអង្គ។

៤ អ្វីៗមានដំណោះស្រាយនៅជុំវិញឈើឆ្កាង និងព្រះបន្ទូលរបស់ព្រះយេស៊ូគ្រិស្ត។

នៅពេលដែលក្រុមជំនុំមានទំនាក់ទំនងត្រឹមត្រូវចំពោះព្រះ ក្រុមជំនុំមានចិត្តឆេះឆួលសម្រាប់បេសកកម្មរបស់ព្រះ។ នៅពេលដែលក្រុមជំនុំយល់ផែនការរបស់ព្រះសម្រាប់សហគមន៍ ក្រុមជំនុំមាននិមិត្ត។ បន្ទាប់មក ក្រុមជំនុំប្រុងប្រៀបជាស្រេចនឹងអនុវត្តបេសកកម្មនៅក្នុងសហគមន៍របស់ខ្លួន។ ព្រះពររបស់ព្រះ ធ្វើឲ្យក្រុមជំនុំលូតលាស់ ពេលក្រុមជំនុំមានទីបន្ទាល់ ទាំងនៅក្នុងពាក្យសម្តី និងសកម្មភាពក្នុងសហគមន៍។

## សេចក្តីសន្និដ្ឋាន:

រឿងរបស់នាងផ្លរិនស៍ ឆាដវិក - Florence Chadwick, 4 កក្កដា 1952, កោះ Catalina

## ការអញ្ជើញ:

### ប្រសិនបើមិនមែនថ្ងៃនេះ តើពេលណា? ប្រសិនបើមិនមែនខ្ញុំ តើជានរណា?

សំណួរសម្រាប់យើងជាអ្នកដឹកនាំគ្រិស្តបរិស័ទ គឺដូចគ្នា។ តើយើងមាននិមិត្តរបស់ព្រះសម្រាប់សហគមន៍របស់យើង នៅក្នុងចិត្តរបស់យើងឬទេ? តើយើងត្រៀមប្រយុទ្ធនឹងព្យុះភ្លៀង ដើម្បីសម្រេចគោលបំណង ដែលព្រះមានសម្រាប់យើងឬទេ?

## មេរៀនទី២|

# កត្តាផ្សំទាំងប្រាំនៃក្រុមជំនុំ ដែលមានសុខភាពល្អ

### សេចក្តីផ្តើម:

វគ្គនេះផ្តល់ជូនការពណ៌នាមួយអំពីកត្តាផ្សំដ៏សំខាន់ប្រាំ នៃក្រុមជំនុំដែលមានសុខភាពល្អ:

១ និមិត្តច្បាស់
២ ការអ្នកដឹកនាំដែលមានសិទ្ធិអំណាច
៣ សមាជិកចូលរួមនៅក្នុងព័ន្ធកិច្ច
៤ ភាពជាអ្នកមើលខុសត្រូវលើធនធាន
៥ ការតភ្ជាប់រវាងអត្ថបទ និងបរិបទ

ការយល់ដឹងកត្តាផ្សំទាំងនេះ ជួយអ្នកដឹកនាំឲ្យមានសមត្ថភាពធ្វើផែនការយុទ្ធសាស្រ្ត ហើយវាយតម្លៃព័ន្ធកិច្ចរបស់ខ្លួន។



**ឧទាហរណ៍** | បុរសនៅលើផ្លូវរថភ្លើង។

ដើម្បីឲ្យមានក្រុមជុំនុំមួយដែលលូតលាស់ និងមានសុខភាព យើងត្រូវយកចិត្តទុកដាក់គ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ក្រុមជុំនុំ និងព័ន្ធកិច្ច (កត្តាផ្សំទាំងប្រាំ និងតួនាទីទាំងប្រាំ)។

**ដ្យាក្រាម** | "សញ្ញាណសំខាន់ៗនៃក្រុមជំនុំដែលមានសុខមាលភាព"។




**បុរសនៅលើផ្លូវរថភ្លើង** | មានបុរសម្នាក់ ថ្ងៃមួយ បានចេញដើរលេងនៅលើផ្លូវរថភ្លើង។ គាត់បានដឹងថា ផ្លូវដែកដែលគាត់ដើរពីលើនោះ ចាប់ផ្តើមញ័ររញ្ជួយ ប៉ុន្តែ គាត់ពុំឃើញមានរថភ្លើងណាមកទេ ដូច្នេះ គាត់ក៏បន្តដើរទៅមុខទៀត។ បន្ទាប់មក គាត់បានឮសូររថភ្លើង ដែលហាក់ដូចជានៅក្បែរគាត់ ប៉ុន្តែគាត់ពុំឃើញមានរថភ្លើងណា នៅពីមុខគាត់សោះ ដូច្នេះ គាត់ក៏សម្រេចចិត្តបន្តដើរទៅទៀត។ តើមានអ្វីកើតឡើង ក្រោយមកទៀត? [គាត់ត្រូវរថភ្លើងមកពីខាងក្រោយបុក]។ បុរសនេះជឿទុកចិត្តលើអ្វីដែលភ្នែកគាត់មើលឃើញតែប៉ុណ្ណោះ ហើយមិនបានដឹងថា មានរថភ្លើងខាងក្រោយកំពុងតម្រង់មករកគាត់ទេ។ ការមិនយកចិត្តទុកដាក់នឹងសញ្ញាដែលនៅជុំវិញយើង អាចនាំឲ្យអន្តរាយ! ដូចគ្នានេះដែរ នៅក្នុងក្រុមជំនុំ យើងត្រូវពិចារណាគ្រប់សញ្ញាទាំងអស់ នៃអ្វីដែលកំពុងតែកើតឡើងនៅក្នុងជីវិតរបស់ក្រុមជំនុំ មិនមែនតែពីរបីចំណុចប៉ុណ្ណោះទេ។

ចំណុចនៅក្នុងមេរៀនទី២ និងទី៣ គឺថា ដើម្បីឲ្យមានក្រុមជំនុំមួយ ដែលលូតលាស់ និងមានសុខភាព យើងត្រូវយកចិត្តទុកដាក់អភិវឌ្ឍគ្រប់ផ្នែកទាំងអស់ នៃជីវិតក្រុមជំនុំ។ បើមិនដូច្នោះទេ ក្រុមជំនុំទាំងមូលនឹងរងទុក្ខ។

ចំណុចទាំង១០ នៃក្រុមជំនុំដែលមានសុខភាព (កត្តាផ្សំទាំងប្រាំ នៅក្នុងមេរៀនទី២ និងតួនាទីទាំងប្រាំនៅក្នុងមេរៀនទី៣) មានទំនាក់ទំនងគ្នាទៅវិញទៅមក និងមានសារសំខាន់ចំពោះក្រុមជំនុំណាស់ មិនថាក្រុមជំនុំនោះ ស្ថិតនៅក្នុងកម្រិតចាស់ទុំប៉ុនណានោះទេ។

បន្ទាប់ពីពណ៌នាកត្តាផ្សំ និងតួនាទីនីមួយៗ មានប្រយោគខ្លះ ដែលសិក្ខាកាមអាចឆ្លើយតបបាន ដើម្បីវាយតម្លៃក្រុមជំនុំរបស់ពួកគេ។

**និមិត្តច្បាស់** | ចំណុចនានាអំពីនិមិត្ត ដែលលក្ខណៈទេវសាស្ត្រ និងស្របតាមព្រះគម្ពីរ (អ្វីដែលព្រះត្រាស់ហៅក្រុមជំនុំឲ្យមានភាពបែបណា និងឲ្យធ្វើអ្វី) យើងបានបង្ហាញជូននៅក្នុងមេរៀនទី១។ នៅទីនេះ យើងបញ្ជាក់ប្រាប់អំពីតួនាទីនៃប្រយោគនិមិត្ត នៅក្នុងក្រុមជំនុំមូលដ្ឋាន។ ចំណុចសំខាន់នានានៃប្រយោគនិមិត្ត គឺការដែលស្របជាមួយសេចក្តី ដែលព្រះទ្រង់បង្រៀននៅក្នុងព្រះគម្ពីរ មានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ និងត្រូវបានរៀបរាប់ប្រាប់ ម្តងហើយម្តងទៀត ហើយទាំងសមាជិក និងអ្នកដឹកនាំបានចាប់យកទាំងអស់គ្នា។

**ការវិភាគអំពីប្រយោគនិមិត្ត|** អញ្ជើញមនុស្ស ដើម្បីជួយរកឲ្យឃើញអំពីរបៀប ដែលប្រយោគនិមិត្តគំរូនោះ ឆ្លុះបញ្ចាំងអំពីកត្តាសំខាន់ទាំង៨។ តើនិមិត្តនេះបង្ហាញរូបភាពមួយច្បាស់ អំពីអនាគតដែលគេចង់បានឬទេ? តើជួយមនុស្សឲ្យមើលឃើញអ្វីៗ ដែលចេញពីទស្សនៈរបស់ព្រះឬទេ? តើប្រយោកនិមិត្តនោះ មានមូលដ្ឋាននៅលើគោលបំណងប្រោសលោះរបស់ព្រះឬទេ? ។ល។

## **១. និមិត្តច្បាស់** | ១ពេត្រុស ២:៩ និង១២

ក្រុមជំនុំមើលឃើញច្បាស់ថា ព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំទៅជាអ្វី និងធ្វើអ្វី ក្នុងនាមជារូបកាយរបស់ព្រះគ្រិស្ត តាមរយៈសកម្មភាពនៅកន្លែងមួយ និងពេលវេលាមួយជាក់លាក់។ និមិត្តស្របជាមួយនឹងគោលបំណងប្រោសលោះរបស់ព្រះ និងផ្តោតក្រុមជំនុំទៅលើបេសកកម្មរបស់ខ្លួន។ នៅក្នុងក្រុមជំនុំមួយដែលមានសុខភាពល្អ ការសម្រេចចិត្តអំពីព័ន្ធកិច្ច ថវិកា និងអាគារ។ល។ ត្រូវធ្វើឡើងផ្អែកទៅលើបេសកកម្ម។

ចំណុចសំខាន់ទាំង៨ នៃប្រយោគនិមិត្តៈ

១ និមិត្តបង្ហាញរូបភាពច្បាស់អំពីអនាគតដែលចង់បាន។
២ និមិត្តជំរុញមនុស្សឲ្យគិតអំពីលទ្ធភាព «ដោយពាក់វ៉ែនតា» របស់ព្រះ។
៣ និមិត្តផ្អែកលើគោលបំណងប្រោសលោះរបស់ព្រះ។
៤ និមិត្តគឺមិនស្កប់ចិត្តនឹងអ្វីដែលកំពុងតែមាន (របៀបដែលអ្វីៗកំពុងមាននៅបច្ចុប្បន្ន)។
៥ និមិត្តត្រូវប្រើជំនឿ។
៦ និមិត្តផ្សព្វផ្សាយប្រាប់មនុស្សតាមបែបមួយសាមញ្ញ។
៧ និមិត្តនាំទៅរកការអធិស្ឋាន ហើយសកម្មភាព/និមិត្តនោះ នាំឲ្យយល់ថាកិច្ចការបន្ទាន់។
៨ និមិត្តចែកចាយប្រាប់ក្នុងចំណោមអ្នកដឹកនាំ និងសមាជិក។

### ប្រយោគនិមិត្តមួយ ត្រូវវិភាគអំពីៈ

*«និមិត្តរបស់យើងគឺថា គ្រប់មនុស្ស គ្រប់គ្រួសារទាំងអស់នៅក្នុងក្រុងរបស់យើង មានឱកាសទទួលព្រះគ្រិស្ត ជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់ ចម្រើនឡើងក្នុងការយល់ដឹងអំពីព្រះអង្គ ហើយប្រើទេពកោសល្យ និងធនធានរបស់ខ្លួន ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះអង្គ»។*

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំលោកអ្នក។

អានប្រយោគនីមួយៗ ហើយកំណត់នៅក្នុងគំនិតលោកអ្នក។ (លេខ «១» កំណត់ថា លោកអ្នកមិនឯកភាពទាំងស្រុងទៅនឹងប្រយោគនេះ លេខ «១០» កំណត់ថាលោកអ្នកឯកភាពទាំងស្រុង)។

- ក្រុមជំនុំរបស់យើងមាននិមិត្តត្រឹមត្រូវ និងច្បាស់លាស់សម្រាប់ពេលអនាគត។

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|

- ខ្ញុំមានអារម្មណ៍ថានិមិត្តរបស់ក្រុមជំនុំជម្រុញចិត្តខ្ញុំ។

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|

## ២. ភាពជាអ្នកដឹកនាំដែលទទួលបានសិទ្ធិអំណាច | អេភេសូរ ៤:១១-១២

ក្រុមជំនុំត្រូវបានបម្រើដោយអ្នកដឹកនាំដែលព្រះត្រាស់ហៅ ដែលយល់និមិត្តរបស់ក្រុមជំនុំ និងរៀបរាប់ប្រាប់ក្រុមជំនុំច្បាស់ៗអំពីនិមិត្ត ហើយចាត់ចែងសមាជិក ដើម្បីធ្វើឲ្យនិមិត្តនោះក្លាយជាការពិត។

**ចរិតលក្ខណៈរបស់អ្នកដឹកនាំនៅក្នុងបទគម្ពីរ:**

១ អ្នកដឹកនាំ ជាមនុស្សដែលព្រះបានចាត់ (យ៉ូហាន ១៧:១៨)
២ អ្នកដឹកនាំ ជាអ្នកបម្រើ (ភីលីព ២:៥-៨; ម៉ាកុស ១០:៤២-៤៥; យ៉ូហាន ១៣:១៣-១៥)
៣ អ្នកដឹកនាំស្វែងរកការដឹកនាំរបស់ព្រះ (ទំនុកតម្កើង ២៥:៤-៥)
៤ អ្នកដឹកនាំ ជាអ្នកជំរុញចិត្ត និងបំពាក់បំប៉នប្រជារាស្រ្តរបស់ព្រះ (អេភេសូរ ៤:១១-១២ និង ២ធីម៉ូថេ ២:២).

**ភាពផ្ទុយគ្នារវាងការដឹកនាំ:**

| អ្នកដឹកនាំដែលប្រើអំណាចត្រួតត្រា | អ្នកដឹកនាំ ដែលបម្រើ |
|---|---|
| និយាយថា៖ «ត្រូវធ្វើតាមខ្ញុំ!» | និយាយថា៖ «ត្រូវធ្វើតាមព្រះយេស៊ូ!» |
| កំណត់អ្វីដែលជានិមិត្ត និងជាគោលបំណងរបស់ខ្លួនសម្រាប់ក្រុមជំនុំ។ | ធ្វើការជាមួយអ្នកដឹកនាំ ដើម្បីស្វែងយល់និមិត្ត និងគោលបំណងដែលព្រះមានសម្រាប់ក្រុមជំនុំ។ |
| មិនប្រគល់សិទ្ធិ មានតែបញ្ជា។ | ឲ្យអ្នកដទៃមានចំណែក។ |
| សម្រេចចិត្តដោយខ្លួនឯង។ | សូមឲ្យអ្នកដទៃចូលរួមធ្វើការសម្រេចចិត្ត។ |
| រអ៊ូរទាំអំពីភាពទន់ខ្សោយរបស់ក្រុមជំនុំ។ | ពង្រឹងចំណុចដែលទន់ខ្សោយរបស់ក្រុមជំនុំ។ |
| ធ្វើអ្វីៗតែខ្លួនឯងៈ អធិប្បាយ សួរសុខទុក្ខ អធិស្ឋាន បង្រៀន ដឹកនាំថ្វាយបង្គំ។ល។ | បង្ហាត់អ្នកដទៃឲ្យធ្វើព័ន្ធកិច្ច ហើយលើកទឹកចិត្តពួកគេ។ |
| មើលឃើញអ្នកដឹកនាំផ្សេងទៀតថាជាគូប្រជែង និងជាការគម្រាម។ | មើលឃើញអ្នកដឹកនាំផ្សេងទៀត ថាជាដៃគូ និងជាព្រះពរ។ |

ការគិតថា មានតែគ្រូគង្វាលម្នាក់ប៉ុណ្ណោះដែលអាចធ្វើកិច្ចការទាំងអស់បាននៅក្នុងក្រុមជំនុំ មិនត្រឹមតែជាគំនិតលេលាទេ តែមិនស្របតាមព្រះគម្ពីរទៀតផង។ នៅក្នុងនិក្ខមនំ ១៨:១៣-២៧ លោកម៉ូសេបានរៀនអំពីរបៀបប្រគល់សិទ្ធិអំណាចដល់អ្នកផ្សេងទៀតឲ្យធ្វើព័ន្ធកិច្ច ដើម្បីឲ្យមនុស្សអាចទទួលបានការយកចិត្តទុកដាក់ដែលពួកគេត្រូវការ ហើយគាត់ខ្លួនឯងមិនរែកពុនហួសបន្ទុក។

**ការឆ្លុះបញ្ចាំង** | តើលោកអ្នកដាក់អ្នកដទៃឲ្យធ្វើការឬទេ? តើនរណាខ្លះនៅក្នុងក្រុមជំនុំរបស់លោកអ្នក ដែលលោកអ្នកអាចឲ្យមានចំណែកផ្សេងៗគ្នា?

**ភាពជាអ្នកដឹកនាំដែលទទួលបានសិទ្ធិអំណាច** | សង្កត់ធ្ងន់អំពីអ្វីដែលអេភេសូរ ៤:១០-១២ បង្រៀនអំពីតួនាទីរបស់អ្នកដឹកនាំនៅក្នុងការហ្វឹកហ្វឺន និងធ្វើឲ្យសមាជិកទាំងអស់មានចលនាសម្រាប់ព័ន្ធកិច្ច។ ការងារអ្នកដឹកនាំ គឺស្គាល់អ្វីជានិមិត្តរបស់ក្រុមជំនុំ រៀបរាប់ច្បាស់ៗប្រាប់ក្រុមជំនុំអំពីនិមិត្ត ហើយចាត់ចែងសមាជិកប្រើអំណោយទាន និងធនធានរបស់ពួកគេសម្រេចនិមិត្តនោះ។ ចំណុច «គ្រូគង្វាលធ្វើសព្វគ្រប់» ចប់ហើយ មានតែគ្រូគង្វាលជាអ្នកបំពាក់បំប៉នប៉ុណ្ណោះនៅទីនេះ។ គ្រូគង្វាលគួរតែលែងព្យាយាមធ្វើអ្វីៗទាំងអស់តែម្នាក់ឯងទៀតទៅ ផ្ទុយទៅវិញ គួរតែដឹកនាំអ្នកដទៃឲ្យប្រើអំណោយទានរបស់ពួកគេនៅក្នុងព័ន្ធកិច្ច។ គ្រប់គ្នាមានអំណោយទានដែលត្រូវប្រើដើម្បីប្រទានពរដល់អ្នកដទៃទាំងនៅខាងក្នុង និងខាងក្រៅក្រុមជំនុំ។

**រូបកាយដែលមានចលនា** | សមាជិកក្រុមជំនុំធ្វើការទាំងអស់គ្នា ប្រើអំណោយទានរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវនៅក្នុងក្រុមជំនុំ និងសហគមន៍។ សង្កត់ធ្ងន់លើការជួយមនុស្សម្នាក់ៗ ឲ្យរកឃើញនូវអ្វីដែលជាអំណោយទានរបស់ខ្លួន ហើយឲ្យប្រើអំណោយទាននោះ។

**ចែកចាយប្រាប់រឿងខាងក្រោម**| ពេលមួយ អ្នកដឹកនាំថ្នាក់សិក្សាព្រះគម្ពីរបានចែកអំណោយម្នាក់កញ្ចប់ៗ ដល់សមាជិកក្នុងក្រុម។ គាត់បានសួរថា៖ «តើយើងគួរធ្វើដូចម្តេច ជាមួយអំណោយទាំងនេះ?» ពិតណាស់ ពួកគេឆ្លើយថា យើងត្រូវបើកកញ្ចប់នោះមើល។ ក្នុងកញ្ចប់នីមួយៗ គេឃើញមានដុំបំណែកមួយនៃរូបភាពផ្គុំ។ បន្ទាប់មក អ្នកដឹកនាំសួរថា៖ «តើយើងត្រូវធ្វើដូចម្តេចជាមួយបំណែកនេះ?» បន្ទាប់មក សមាជិកដឹងថា ពួកគេត្រូវតែដាក់បំណែកទាំងនោះរួមគ្នា ដើម្បីឲ្យដឹងថារូបផ្គុំនោះជាអ្វី។ ពួកគេបានដាក់ចំណែករបស់ពួកគេទាំងអស់គ្នា ប៉ុន្តែ គេដឹងថា មានបាត់ផ្នែកខ្លះ! អ្នកដឹកនាំថ្នាក់សិក្សាព្រះគម្ពីរ ប្រាប់ពួកគេថា៖ «ឥឡូវនេះ យើងត្រូវរកមនុស្សថែមទៀត ដើម្បីឲ្យគេទទួលព្រះគ្រិស្ត ដើម្បីឲ្យអំណោយទានរបស់ពួកគេ បានរួមគ្នាសម្រេចកិច្ចការក្រុមជំនុំ»។

**សួរ** | គ្រិស្តបរិស័ទម្នាក់ៗសុទ្ធតែមានអំណោយទានដែលត្រូវប្រើ។ តើលោកអ្នកដឹងថា អំណោយទានរបស់លោកអ្នកជាអ្វីឬទេ? តើក្រុមជំនុំរបស់លោកអ្នកជួយមនុស្សឲ្យស្គាល់អំណោយទានរបស់ខ្លួន ហើយប្រើអំណោយទានទាំងនោះឬទេ?

**នាំសមាជិកឲ្យចូលរួមបម្រើ** | សមាជិកក្រុមជំនុំទាំងអស់ ត្រូវចាស់ទុំខាងទំនាក់ទំនងជាមួយព្រះ (បង្រៀនគេ) ហ្វឹកហ្វឺនឲ្យបម្រើ និងជួយឲ្យរកឃើញព័ន្ធកិច្ចដែលត្រូវប្រើអំណោយទានរបស់គេ។ សូមឲ្យសិក្ខាកាមចាប់ដៃគូ ឬជាក្រុមតូចៗ ដើម្បីពិភាក្សារកឲ្យឃើញរបៀបដែលក្រុមជំនុំរបស់គេ អាចបំពេញព័ន្ធកិច្ច តាមប្រភេទនីមួយៗ។ សុំពួកគេរកឲ្យឃើញប្រភេទណាខ្លះដែលមានសកម្មភាពគ្រប់គ្រាន់ និងប្រភេទណាខ្លះដែលត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែម។

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- មានអ្នកដឹកនាំដែលទទួលបានការហ្វឹកហ្វឺន និងត្រៀមសម្រាប់តួនាទីដឹកនាំនៅពេលអនាគត។

1 2 3 4 5 6 7 8 9 10

- អ្នកដឹកនាំជួយ ហើយណែនាំអស់អ្នកដែលមានចិត្តចង់ ដើម្បីឲ្យគេមានសកម្មភាពបម្រើក្នុងក្រុមជំនុំ។

1 2 3 4 5 6 7 8 9 10

## ៣. រូបកាយដែលមានចលនា | ១កូរិនថូស ១២:៧; ១ពេត្រុស ៤:១០-១១

សមាជិកក្រុមជំនុំធ្វើការទាំងអស់គ្នា ប្រើអំណោយទានរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនៅក្នុងក្រុមជំនុំ និងសហគមន៍។ គ្រូគង្វាលដែលមានប្រសិទ្ធភាព ដឹងរបៀបលើកទឹកចិត្តសមាជិកក្រុមជំនុំ ឲ្យមានចំណែកនៅក្នុងព័ន្ធកិច្ច។ គាត់ផ្តល់សិទ្ធិការងារដល់អ្នកដទៃ ដើម្បីឲ្យពួកគេអាចប្រើអំណោយទានរបស់ខ្លួន។

**ការងារមានជោគជ័យ នៅពេលដែលក្រុមចូលរួម:**

១ មានគោលដៅច្បាស់លាស់ ហើយជំរុញចិត្ត
២ ធ្វើការដោយមានរចនាសម្ព័ន្ធ ដើម្បីសម្រេចលទ្ធផល
៣ សមាជិកមានសមត្ថភាព
៤ មានការប្តេជ្ញាចិត្តរបស់សមាជិកគ្រប់រូប
៥ មានបរិយាកាសសហការ
៦ មានខ្នាតមួយនៃភាពវិសេស
៧ មានការដឹកនាំដែលបម្រើ

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- ក្រុមជំនុំជួយសមាជិកឲ្យរកឃើញអំណោយទានរបស់ខ្លួនសម្រាប់ព័ន្ធកិច្ច។

1 2 3 4 5 6 7 8 9 10

- ខ្ញុំបានទទួលការហ្វឹកហ្វឺនឲ្យបម្រើ និងដឹកនាំក្នុងក្រុមជំនុំ និងសហគមន៍។

1 2 3 4 5 6 7 8 9 10

## លំហាត់ | ជំរុញសមាជិកធ្វើព័ន្ធកិច្ច

**សេចក្តីណែនាំ** | គិតអំពីព័ន្ធកិច្ចដែលកំពុងមាននៅក្នុងក្រុមជំនុំរបស់លោកអ្នក និងរាយបញ្ជីអំពីព័ន្ធកិច្ចទាំងនោះទៅតាមប្រភេទខាងក្រោម៖

| ឱបក្រសោបមនុស្ស | សង់មនុស្ស | បំពាក់បំប៉នមនុស្ស | បំផុសចលនាមនុស្ស |
|---|---|---|---|
| របៀបដែលលោកអ្នកនាំមនុស្សឲ្យមានទំនាក់ទំនងជាមួយក្រុមជំនុំ ធ្វើឲ្យពួកគេមានអារម្មណ៍ទទួលបានការស្វាគមន៍ ហើយហៅគេឲ្យមានទំនាក់ទំនងជាមួយព្រះយេស៊ូគ្រិស្ត (ឧ. កម្មវិធីថ្វាយបង្គំពិសេសណាៗ ការប្រគុំតន្ត្រី គម្រោងផ្តល់សេវាសហគមន៍ ការរាប់អានជាមួយអ្នកមិនជឿ ការប្រកាសដំណឹងល្អតាមផ្ទះ។ល។) | ជារបៀបដែលលោកអ្នកបង្រៀនអ្នកដទៃឲ្យក្លាយជាសិស្ស និងជួយពួកគេឲ្យលូតលាស់នៅក្នុងជំនឿ (ក្រុមសិក្សាព្រះគម្ពីរ ថ្នាក់ថ្ងៃអាទិត្យ ដៃគូការអធិស្ឋាន ថ្នាក់បង្រៀនសមាជិកថ្មីៗ ព័ន្ធកិច្ចស្ត្រី ព័ន្ធកិច្ចបុរស ទំនាក់ទំនងផ្តល់ឱវាទ។ល។) | របៀបដែលលោកអ្នកហ្វឹកហ្វឺនមនុស្សសម្រាប់ព័ន្ធកិច្ចជាក់លាក់ ហើយជួយពួកគេឲ្យស្គាល់អំណោយទាន និងអភិវឌ្ឍអំណោយទានទាំងនោះ (ការថ្វាយបង្គំបែបប្រកាសដំណឹងល្អ ថ្នាក់និយាយអំពីអំណោយទានខាងវិញ្ញាណ សិក្ខាសាលានិយាយអំពីថវិកាសម្រាប់គ្រួសារ ហ្វឹកហ្វឺនមនុស្សដឹកនាំការថ្វាយបង្គំ ឬអធិប្បាយ ការហ្វឹកហ្វឺនសម្រាប់អ្នកដឹកនាំក្រុមតូច ។ល។) | របៀបដែលមនុស្សប្រើអំណោយទានពិតប្រាកដរបស់ពួកគេទាំងនៅខាងក្នុង និងខាងក្រៅក្រុមជំនុំ (ការរៀបចំអាហារ ការចុះសួរសុខទុក្ខ បង្រៀន ដឹកនាំចម្រៀងថ្វាយបង្គំ ដឹកនាំថ្នាក់ណាមួយទៅតាមសកម្មភាពជាក់ស្តែងដែលពួកគេស្ទាត់ជំនាញ មានការបោះជំរុំបាល់ទាត់សម្រាប់ក្មេងៗនៅជិតខាង សម្អាតព្រះវិហារ។ល។) អ្វីៗដែលមនុស្សអាចធ្វើបានអាចរាប់បញ្ចូលទៅក្នុងព័ន្ធកិច្ចរបស់ក្រុមជំនុំ។ |

ឥឡូវនេះ ពិនិត្យមើលបញ្ជីរបស់លោកអ្នកឡើងវិញ ដើម្បីឲ្យឃើញដែលក្រុមជំនុំរបស់លោកអ្នកមានប្រសិទ្ធភាពបំផុត និងចំណុចដែលលោកអ្នកត្រូវយកចិត្តទុកដាក់បន្ថែម។

| ឱបក្រសោបមនុស្ស | សង់មនុស្ស | បំពាក់បំប៉នមនុស្ស | បំផុសចលនាមនុស្ស |
|---|---|---|---|
| | | | |

**ជាមួយអ្នកដឹកនាំរបស់លោកអ្នក សូមរំលឹកឡើងវិញអំពីលំហាត់ជំរុញសមាជិកឲ្យចូលរួមព័ន្ធកិច្ច:**

១. រៀបរាប់សកម្មភាពដែលក្រុមជំនុំលោកអ្នកមាន សម្រាប់ប្រភេទនៃព័ន្ធកិច្ចនីមួយៗ
២. សូមសួរថា តើសកម្មភាពដែលលោកអ្នករៀបរាប់តាមប្រភេទនីមួយៗ មានប្រសិទ្ធភាពនៅក្នុងចំណុចនោះ ឬយ៉ាងណា
៣. សូមកំណត់កន្លែងដែលលោកអ្នកត្រូវធ្វើសកម្មភាព និងអ្វីដែលត្រូវសម្រេចឲ្យបាន។

## ៤. ភាពជាអ្នកមើលការខុសត្រូវលើធនធាន | ១កូរិនថូស ៤:២; សុភាសិត ៣:៩-១០; ១កូរិនថូស ៦:១៩-២០; កិច្ចការ ២០:៣៥

ក្រុមជំនុំជំរុញសមាជិករបស់ខ្លួន ឲ្យធ្វើជាអ្នកមើលការខុសត្រូវល្អលើទ្រព្យសម្បត្តិរបស់ក្រុមជំនុំឲ្យបានល្អ ដូចជារបស់ខ្លួន។ គ្រិស្តបរិស័ទទាំងអស់ អាចប្រើធនធានទាំងនេះ (ពេលវេលា ទេពកោសល្យ និងទ្រព្យសម្បត្តិ) ដើម្បីបំពេញកិច្ចការរបស់ខ្លួននៅក្នុងព្រះរាជ្យរបស់ព្រះ ទាំងនៅក្នុងក្រុមជំនុំ និងនៅក្នុងសហគមន៍។ ក្រុមជំនុំខ្លួនឯង ត្រូវប្រើធនធានយ៉ាងឆ្លាតវៃ និងដោយតម្លាភាព។

**អក្សរ «T's» ទាំងបួននៃភាពជាអ្នកមើលការខុសត្រូវ:**

១. <u>T: TIME ពេលវេលា</u>
២. T: Talent ទេពកោសល្យ
៣. **T: TREASURE ទ្រព្យសម្បត្តិ**
៤. T: Temple of God វិហាររបស់ព្រះ (រូបកាយរបស់យើង)

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- ក្រុមជំនុំរបស់បំពេញតួនាទីជាអ្នកមើលការខុសត្រូវបានល្អ ក្នុងការគ្រប់គ្រងថវិកា។

1 2 3 4 5 6 7 8 9 10

- ក្រុមជំនុំរបស់យើងបង្រៀនជាទៀងទាត់អំពីភាពជាអ្នកមើលការខុសត្រូវ និងការថ្វាយតង្វាយ។

1 2 3 4 5 6 7 8 9 10

**ភាពជាអ្នកមើលការខុសត្រូវលើធនធាន** | ក្រុមជំនុំជំរុញសមាជិករបស់ខ្លួន ឲ្យធ្វើជាអ្នកមើលការខុសត្រូវល្អលើទ្រព្យសម្បត្តិរបស់ពួកគេមាន ពេលវេលា ទ្រព្យសម្បត្តិ ទេពកោសល្យ និងព្រះវិហាររបស់ព្រះ (រូបកាយរបស់យើង) ដើម្បីពង្រីកព្រះរាជ្យរបស់ព្រះនៅក្នុងក្រុមជំនុំ និងនៅក្នុងសហគមន៍។ ក្រុមជំនុំខ្លួនឯង ក៏ត្រូវធ្វើជាអ្នកមើលការខុសត្រូវល្អ លើធនធានរបស់ខ្លួនឯងដែរ។

**គំរូអំពីភាពជាអ្នកមើលការខុសត្រូវ** |

- ក្រុមជំនុំថែទាំអាគារ និងសម្ភារៈបានល្អ
- អ្នកជំនួយ ឬគណៈកម្មការពិសេស ជាអ្នករាប់ និងជាអ្នកគ្រប់គ្រងថវិកា មិនមែនគ្រូគង្វាល។ ពួកគេកត់ត្រាជាប់ជានិច្ចយ៉ាងត្រឹមត្រូវ នូវរបាយការណ៍តង្វាយ ព្រមទាំងរាយការណ៍ជាប្រចាំប្រាប់ក្រុមជំនុំអំពីខ្ទង់ចំណាយ។
- ក្រុមជំនុំលើកទឹកចិត្តមនុស្ស ឲ្យប្រើពេលវេលារបស់ខ្លួនឲ្យបានល្អ (ថែទាំគ្រួសារ ធ្វើការបម្រើនៅក្នុងក្រុមជំនុំ និងសហគមន៍)។
- ក្រុមជំនុំកែតម្រូវថវិកាឲ្យត្រូវ ទៅតាមនិមិត្តរបស់ខ្លួន។

ជានិច្ចកាល ក្រុមជំនុំដ៏មានចេស្តា តែកំណត់ធនធានរបស់ខ្លួន ហើយវិនិយោគអ្វីដែលខ្លួនមានទៅក្នុងព័ន្ធកិច្ច និងបេសកកម្ម មិនមែនរក្សាធនធានទុកសម្រាប់ខ្លួនឯងទេ។ សុំឲ្យសិក្ខាកាមលើកឧទាហរណ៍អំពីរបៀបដែលក្រុមជំនុំរបស់គេ ជួយមនុស្សឲ្យចេះចាត់ចែងពេលវេលា ទេពសកោសល្យ ទ្រព្យសម្បត្តិ និងរូបកាយដែលជាព្រះវិហារ ឲ្យបានល្អ។ សុំឲ្យគេចែកចាយប្រាប់ដៃគូរបស់ខ្លួន អំពីរបៀបដែលក្រុមជំនុំរបស់គេចាត់ចែងថវិកា និងការកត់ត្រា។

## ៨. ការតភ្ជាប់រវាងអត្ថបទ និងបរិបទ | ២ធីម៉ូថេ ៣:១៦-១៧ កិច្ចការ ១៧:២២-២៣ និង ១កូរិនថូស ៩:១៩-២២ ម៉ាថាយ ៩:៣៥-៣៨

ក្រុមជំនុំសុខភាពល្អ ដំណើរការទៅតាមបរិបទរបស់ខ្លួន (ទីតាំងភូមិសាស្ត្រ កត្តាសេដ្ឋកិច្ច និងសង្គម វប្បធម៌។ល។) រាជសារនៃដំណឹងល្អនៅក្នុងព្រះយេស៊ូគ្រិស្តមិនប្រែប្រួលឡើយ តែវិធីសាស្ត្រនៃការចែកចាយដំណឹងល្អ អាចមានការប្រែប្រួល។

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- ក្រុមជំនុំរបស់យើងដឹងអំពីសេចក្តីត្រូវការនៅក្នុងបរិបទសង្គមរបស់យើង។

1 2 3 4 5 6 7 8 9 10

- ក្រុមជំនុំរបស់យើងខិតខំអស់ពីសមត្ថភាព ក្នុងការសង់ទំនាក់ទំនងក្នុងសហគមន៍។

1 2 3 4 5 6 7 8 9 10

### សន្និដ្ឋាន:

ក្រុមជំនុំនីមួយៗមានភាពផ្ទាល់ខ្លួន និងសមត្ថភាពដាច់ឡែកគ្នា។ ក្រុមជំនុំដែលខ្លាំងនៅក្នុងចំណុចទាំងប្រាំដែលយើងបានពិភាក្សានៅក្នុងមេរៀននេះ ព្រះវិញ្ញាណបរិសុទ្ធនឹងនាំឲ្យបង្កើតបាននូវការផ្លាស់ប្តូរក្នុងសហគមន៍របស់ខ្លួន ក្នុងព្រះនាមព្រះយេស៊ូ។ ក្រុមជំនុំនឹងអញ្ជើញមនុស្សឲ្យរកឃើញជីវិតថ្មីក្នុងព្រះគ្រិស្ត និងជួយពួកគេឲ្យរស់នៅក្នុងព្រះអង្គ ហើយថ្វាយសិរីរុងរឿងដល់ព្រះ។

សង្កត់ធ្ងន់អំពីបរិបទវប្បធម៌ សេដ្ឋកិច្ច និងសង្គមផ្សេងៗគ្នា ដែលមាននៅក្នុងប្រទេស ខេត្ត ក្រុង និងតំបន់ផ្សេងៗគ្នា។ ចូរពណ៌នាអំពីរបៀប ដែលភាពខុសប្លែកគ្នាទាំងនេះ មានឥទ្ធិពលលើការប្រកាសដំណឹងល្អ របស់ក្រុមជំនុំ ការថ្វាយបង្គំ ការចាត់ចែង និមិត្តការងារ។ល។

២ធីម៉ូថេ ៣:១៦-១៧ | ព្រះបន្ទូលរបស់ព្រះជាមគ្គុទ្ទេសក៍សម្រាប់ជីវិត។
កិច្ចការ ១៧:២២-២៣ | លោកប៉ូលតម្រូវរាជសាររបស់លោក ឲ្យត្រូវទៅនឹងមនុស្ស និងទីកន្លែង។
១កូរិនថូស ៩:១៩-២២ | លោកប៉ូលទាក់ទងជាមួយមនុស្ស ទៅតាមរបៀបដែលគេយល់បាន ដើម្បីឈោងចាប់គេជាមួយនឹងដំណឹងល្អ។
ម៉ាថាយ ៩:៣៥-៣៨ | ព្រះយេស៊ូ យាងចេញទៅរកមនុស្ស ហើយជួបពួកគេនៅកន្លែងដែលពួកគេនៅ។

សកម្មភាពជម្រើស | ក្នុងចំណោមប្រាំចំណុច សូមឲ្យសិក្ខាកាមគិតមើលពីចំណុចណា ដែលក្រុមជំនុំរបស់គេខ្លាំង។ ឲ្យពួកគេចែកចាយប្រាប់គ្នាទៅវិញទៅមក អំពីការនេះជាក្រុមៗ ដែលមានគ្នា៣ ទៅ៤នាក់។ ឲ្យពួកគេរើសយកចំណុចមួយមកប្រើ ហើយបំផុសគំនិតអំពីរបៀបដែលក្រុមជំនុំអាចលូតលាស់នៅក្នុងចំណុចនោះ។

## កំណត់ត្រា ៖

**មេរៀនទី៣|**

# កិច្ចការទាំងប្រាំនៃក្រុមជំនុំដែល មានសុខភាពល្អ

## សេចក្តីផ្តើម:

មេរៀនទី៣ ផ្តល់ជូនការពណ៌នាអំពីកិច្ចការទាំងប្រាំនៃក្រុមជំនុំសុខភាពល្អ: ការថ្វាយបង្គំ ការបម្រើ ការប្រកាសដំណឹងល្អ ការបង្កើតសិស្ស និងការប្រកបគ្នា។ ការវាយតម្លៃក្រុមជំនុំទៅតាមបរិបទនៃកិច្ចការទាំងនេះ នោះនឹងជួយអ្នកដឹកនាំឲ្យចេះធ្វើការយុទ្ធសាស្រ្តរបស់ខ្លួន។

**កិច្ចការសំខាន់ៗទាំងប្រាំ** | កិច្ចការ ២:៤២-៤៧




កិច្ចការនីមួយៗមានឥទ្ធិពលដល់គ្នា

**១. ការប្រកាសដំណឹងល្អ** | កិច្ចការ ២:៤៧; ២ធីម៉ូថេ ៤:១-២; កិច្ចការ ៥:៤២; កូឡូស ១:២៨-២៩

ក្រុមជំនុំប្រកាសទាំងពាក្យសម្តី ទាំងការប្រព្រឹត្តិ ដែលមនុស្សអាចយល់បានថា តាមរយៈព្រះយេស៊ូគ្រិស្ត ព្រះរាជ្យរបស់ព្រះមកដល់ហើយ។ ក្រុមជំនុំប្រកាសឲ្យមនុស្សជឿដំណឹងល្អនេះ ថ្វាយជីវិតរបស់គេដល់ព្រះយេស៊ូ ហើយធ្វើជាសិស្សរបស់ព្រះអង្គ។ ជីវិតរបស់យើង ជាសក្ខីភាពអំពីការកើតជាថ្មីនៅក្នុងព្រះគ្រិស្ត ជា «សេចក្តីប្រកាសដ៏រស់» អំពីអ្វីដែលព្រះជាម្ចាស់បានធ្វើ។

ព្រះជាម្ចាស់ ជាអ្នកបន្ថែមឲ្យមានអ្នកជឿដល់ក្រុមជំនុំ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងចិត្តមនុស្ស នាំឲ្យគេទទួលជីវិតដែលបានប្រទានមក ក្នុងអង្គព្រះគ្រិស្ត។

## សំណួរឆ្លុះបញ្ចាំង:

- តើខ្ញុំបានប្រកាសដំណឹងល្អប្រាប់មនុស្សប៉ុន្មាននាក់ កាលពីពីរសប្ដាហ៍មុន?
- តើមានអ្នកជឿប៉ុន្មាននាក់ ដែលក្រុមជំនុំរបស់យើងបានហ្វឹកហ្វឺនឲ្យចែកចាយអំពីជំនឿរបស់ខ្លួន?

## ការផ្លាស់ប្ដូរបីយ៉ាង ដែលមនុស្សត្រូវដឹង ដើម្បីស្គាល់ព្រះគ្រិស្ដ:

១. **ផ្លាស់ប្ដូរអំណាច** | មនុស្សស្គាល់ភាពទន់ខ្សោយរបស់ខ្លួន ហើយជួបនឹងព្រះចេស្ដារបស់ព្រះក្នុងជីវិត តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលប្រទានជីវិតដល់គេ បំបាក់អំណាចបាបនៅក្នុងជីវិតរបស់គេ ហើយនាំផលផ្លែរបស់ព្រះវិញ្ញាណ ដូចជា សេចក្ដីស្រឡាញ់ អំណរ សេចក្ដីសុខសាន្ដ សេចក្ដីអត់ធ្មត់ សេចក្ដីសប្បុរស ចិត្តសន្ដោស ភាពស្មោះត្រង់ ចិត្តស្លូតបូត និងការចេះគ្រប់គ្រងចិត្ត។

**២. ការផ្លាស់ប្ដូរជំនឿ** | ព្រះជាម្ចាស់បើកភ្នែកមនុស្សឲ្យទទួលស្គាល់ថា ព្រះយេស៊ូជានរណា ដូចព្រះគម្ពីរចែងអំពីព្រះអង្គថា ព្រះអង្គជាព្រះរាជបុត្រានៃព្រះ ដែលមានព្រះជន្មរស់ឡើងវិញ។ មនុស្សនឹងមើលឃើញថា ព្រះជាម្ចាស់មានបន្ទូលតាមរយៈបទគម្ពីរ ហើយអ្វីដែលព្រះអង្គមានបន្ទូល អាចទុកចិត្តបាន។

**៣. ការផ្លាស់ប្ដូរឆន្ទៈ** | មនុស្សថ្វាយជីវិតរបស់ខ្លួនដល់ព្រះគ្រិស្ដ ហើយចុះចូលនឹងព្រះហឫទ័យទ្រង់ គ្រប់ចំណុចទាំងអស់នៃជីវិត។

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

អានប្រយោគនីមួយៗ ហើយពិចារណានៅក្នុងគំនិត ( "1" លោកអ្នកមិនឯកភាពទាំងស្រុងទៅនឹងប្រយោគ "10" លោកអ្នកឯកភាពទាំងស្រុង)។

**៤.** ក្រុមជំនុំរបស់យើងហ្វឹកហ្វឺន ហើយបំពាក់បំប៉នសមាជិកខ្លួន ឲ្យធ្វើបន្ទាល់នៅក្នុងសហគមន៍។

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|

៥. ខ្ញុំផ្ទាល់បានរួមចំណែកក្នុងកិច្ចការដំណឹងល្អរបស់ក្រុមជំនុំយើង។

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|

## ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

- តើក្រុមជំនុំរបស់លោកអ្នក លើកទឹកចិត្តមនុស្សឲ្យឃើញព្រះចេស្ដារបស់ព្រះ ឮសេចក្ដីពិតរបស់ព្រះ ហើយឆ្លើយតបដោយប្ដូរផ្ដាច់អស់ពីចិត្ត ចំពោះព្រះគ្រិស្ដ ដោយរបៀបណា?

## ២. ការបង្កើតសិស្ស | កិច្ចការ ២:៤២; ម៉ាថាយ ២៨:១៨-២០; ២ពេត្រុស ៣:១៨

ក្រុមជំនុំសុខភាពល្អ ជួយមនុស្សគ្រប់វ័យទាំងអស់ឲ្យស្គាល់ព្រះគ្រិស្ត និងស្គាល់ព្រះហឫទ័យរបស់ព្រះអង្គកាន់តែច្បាស់ ដើម្បីឲ្យពួកគេដើរតាមព្រះអង្គគ្រប់ចំណុចទាំងអស់ និងសណ្ឋានទាំងអស់នៃជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ នៅពេលដែលយើងស្គាល់ព្រះអង្គ និងស្គាល់ព្រះហឫទ័យរបស់ព្រះអង្គកាន់តែច្បាស់ ហើយពឹងលើព្រះវិញ្ញាណរបស់ព្រះអង្គ នោះយើងកាន់តែមានលក្ខណៈដូចព្រះគ្រិស្ត នៅក្នុង:

១. ចរិយាសម្បត្តិរបស់យើង
**២. <u>គំនិតរបស់យើង</u>**
៣. ចរិតលក្ខណៈរបស់យើង
**៤. ការប្តូរផ្តាច់របស់យើង**

ដ្យាក្រាម | ជំនឿមួយជ្រុង និងជំនឿគ្រប់ជ្រុង




**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- ពេលដែលមនុស្សថ្មីម្នាក់ទទួលព្រះគ្រិស្ត គាត់នឹងទទួលបានការបង្រៀនឲ្យក្លាយជាសិស្សពីមនុស្សម្នាក់

1 2 3 4 5 6 7 8 9 10

- ក្រុមជំនុំជួយឲ្យខ្ញុំលូតលាស់ខាងវិញ្ញាណ។

1 2 3 4 5 6 7 8 9 10

## ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

- តើក្រុមជំនុំលោកអ្នក ជួយមនុស្សឲ្យលូតលាស់ក្នុងការមានទំនាក់ទំនងជាមួយព្រះយេស៊ូគ្រិស្ត ដោយរបៀបណា?

- តើមានឱកាសអ្វីខ្លះដែលក្រុមជំនុំរបស់យើងផ្តល់ឲ្យមនុស្ស ដើម្បីសិក្សាបទគម្ពីរ និងអនុវត្តបទគម្ពីរនៅក្នុងជីវិតរបស់គេ?

**ការបង្កើតសិស្ស** |

**១.** ចរិយាសម្បត្តិ (ករិយារបស់យើងកាន់តែដូចព្រះយេស៊ូ: ភីលីព ១:២៧ អេភេសូរ ៥:១-២)

**២.** គំនិត (យើងមានគំនិតរបស់ព្រះគ្រិស្ត: ភីលីព ២:៥ ភិលីព ៤:៨)។

**៣.** ចរិតលក្ខណៈ (យើងឆ្លុះបញ្ចាំងពីផលផ្លែនៃព្រះវិញ្ញាណ: កាឡាទី ៥:២២-២៤ អេភេសូរ ៥:១-២)

**៤.** ការប្តូរផ្តាច់ (យើងប្តូរផ្តាច់ខ្លួនចំពោះព្រះហឫទ័យរបស់ព្រះ មិនថាត្រូវបង់ថ្លៃប៉ុនណានោះទេ: ម៉ាថាយ ២៦:៣៩ យ៉ូហាន ៦:៣៨)។

**ជំនឿជាផ្នែក** | ជំនឿគ្រាន់តែជាផ្នែកមួយនៃជីវិតរបស់យើង។ យើងគិតពីព្រះ នៅពេលដែលយើងថ្វាយបង្គំព្រះអង្គ ក្រៅពីពេលនេះ យើងរស់នៅដោយមិនបាច់គិតពីព្រះអង្គទេ។ យើងមិនគិតអំពីរបៀបដែលព្រះមានទំនាក់ទំនងទៅនឹងជីវិតគ្រួសាររបស់យើង ថវិការបស់យើង នយោបាយ កីឡា។ល។

**ជំនឿជាចំណុចរួម** | ជំនឿរបស់យើងនៅក្នុងព្រះយេស៊ូមានឥទ្ធិពលលើរបៀបដែលយើងប្រព្រឹត្តចំពោះគ្រួសាររបស់យើង របៀបដែលយើងរស់នៅក្នុងសហគមន៍ និងប្រទេសជាតិ របៀបដែលយើងលេងកីឡា របៀបដែលយើងចាត់ចែងថវិកា ។ល។ គ្រប់ចំណុចទាំងអស់នៃជីវិតយើងស្វែងរកការគាប់ព្រះហឫទ័យដល់ព្រះ។

- តើមានឱកាសអ្វីខ្លះដែលក្រុមជំនុំរបស់យើងផ្តល់ឲ្យមនុស្ស ដើម្បីអធិស្ឋានជាមួយគ្នា និងអធិស្ឋានឲ្យគ្នាទៅវិញទៅមក?
- តើក្រុមជំនុំរបស់យើងជួយសមាជិកដូចម្តេច សម្រាប់ការរៀនដើរតាមព្រះយេស៊ូនៅក្នុងជីវិតគ្រួសាររបស់ពួកគេ ការសម្រេចចិត្តរបស់ពួកគេ កិច្ចការប្រចាំថ្ងៃរបស់ពួកគេ ការប្រើលុយរបស់ពួកគេ និងការប្រើពេលវេលារបស់ពួកគេ?

**៣. ការបម្រើ** | កិច្ចការ ២:៤៥-៤៦; កាឡាទី ៦:១០; ម៉ាកុស ១២:៣១; យ៉ាកុប ២:១៧

ក្រុមជំនុំជួយគ្រប់ជ្រុងជ្រោយ ដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្ស និងសហគមន៍នៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត ព្រមទាំងអញ្ជើញអ្នកទាំងនោះ ឲ្យធ្វើជាសិស្សរបស់ព្រះអង្គ។

គម្ពីរយ៉ាកុបបញ្ជាក់ច្បាស់ថា ជំនឿគ្មានការប្រព្រឹត្តិ គឺស្លាប់ (យ៉ាកុប ២:៧)។ យើងបម្រើគ្នាមិនមែនដើម្បីរកឲ្យបានសេចក្តីសង្គ្រោះនោះទេ គឺយើងបម្រើដោយចេញពីការដឹងគុណចំពោះអ្វីដែលព្រះបានធ្វើសម្រាប់យើង។

ការបម្រើអ្នកដទៃដោយអំណោយទាន និងធនធានរបស់យើង ជាភស្តុតាងជាក់ស្តែងអំពីសេចក្តីស្រឡាញ់របស់ព្រះចំពោះពួកគេ។

## ការតភ្ជាប់រវាងការបម្រើ និងការប្រកាសដំណឹងល្អ

**១.** ការបម្រើ ជាផលនៃការប្រកាសដំណឹងល្អ: សេចក្តីស្រឡាញ់របស់ព្រះ ធ្វើឲ្យយើងចង់បម្រើអ្នកដទៃ។

**២.** ការបម្រើ ជាស្ពាននាំទៅកាន់ការប្រកាសដំណឹងល្អ: យើងបញ្ចេញសកម្មភាពនៃការបម្រើជាមុន ហើយសកម្មភាពបម្រើទាំងនោះ បើកទ្វារសម្រាប់ការចែកចាយជំនឿរបស់យើង។

**៣.** ការបម្រើអមជាមួយការប្រកាសដំណឹងល្អ: នៅពេលដែលយើងបម្រើអ្នកដទៃ យើងប្រកាសពីសេចក្តីស្រឡាញ់របស់ព្រះដល់គេ នៅក្នុងព្រះគ្រិស្ត។

**ឈំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- ក្រុមជំនុំរបស់យើង ជួយមនុស្ស ដោយផ្តល់ជាសេចក្តីត្រូវការខាងសាច់ឈាម។

1 2 3 4 5 6 7 8 9 10

- មនុស្សក្នុងសហគមន៍ដឹងថា យើងចង់បង្ហាញឲ្យមនុស្សឃើញសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត តាមរបៀបរស់នៅជាក់ស្តែង។

1 2 3 4 5 6 7 8 9 10

## ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

- តើសមាជិកក្រុមជំនុំរបស់យើង បម្រើសហគមន៍របស់ខ្លួនដូចម្តេច?
- តើក្រុមជំនុំរបស់យើងទាំងមូល បម្រើសហគមន៍របស់យើងដូចម្តេច?

## ៤. ការប្រកបគ្នា | កិច្ចការ ២:៤២,៤៤,៤៦; កាឡាទី ៦:២; អេភេសូរ ៤:២៥-២៦; ៥:២

នៅក្នុងក្រុមជំនុំដែលមានសុខភាពល្អ សមាជិករីករាយនឹងគ្នាទៅវិញទៅមក និងជួយសម្រាលបន្ទុកគ្នា បង្ហាញសេចក្តីស្រឡាញ់ និងព្រះហឫទ័យអាណិតសូររបស់ព្រះ។ នេះមានន័យថា យើងត្រូវស្គាល់គ្នា ចែកចាយប្រាប់អំពីជីវិតដល់គ្នា ដើម្បីឲ្យយើងអាចដឹងពីវិធីដ៏ប្រសើរបំផុតក្នុងការជួយ។ ពាក្យក្រិកសម្រាប់ការប្រកបគ្នា គឺ *ខយណូនៀ* មានន័យថា «ជារួម»។ ដូច្នេះ ការប្រកបគ្នារបស់គ្រិស្តបរិស័ទ មុនដំបូងបំផុត ត្រូវមានព្រះគ្រិស្តជាចំណុចរួម ដើម្បីចែកចាយលក្ខណៈរបស់យើង និងអ្វីដែលយើងមាន ដល់បងប្អូនរបស់យើងនៅក្នុងព្រះគ្រិស្ត។ ក្រុមតូចជាវិធីមួយដែលគ្រិស្តបរិស័ទអាចជួយគ្នា និងលូតលាស់ជាមួយគ្នានៅក្នុងជំនឿ។

ក្រុមជំនុំដែលមានសុខភាពល្អយល់ថា ទំនាស់ជាផ្នែកធម្មតាមួយនៃជីវិត ក្នុងនាមជាក្រុមជំនុំ។ ពួកគេដោះស្រាយទំនាស់តាមរបៀបសង់ ដោយផ្តោតទៅលើរបៀបដោះស្រាយស្ថានភាព ដើម្បីឲ្យក្រុមជំនុំនៅតែស្មោះត្រង់ចំពោះនិមិត្តរបស់ខ្លួន ហើយនិយាយសេចក្តីពិតដោយសេចក្តីស្រឡាញ់។ អ្នកដឹកនាំត្រូវតែមានសេចក្តីស្រឡាញ់ និងការគោរព ប៉ុន្តែម៉ឺងម៉ាត់។ នៅពេលដែលសមាជិក ឬអ្នកដឹកនាំមិនធ្វើតាមការណែនាំនៅក្នុងព្រះគម្ពីរ ពួកគេត្រូវតែទទួលការកែតម្រង់ដោយយកចិត្តទុកដាក់ ប៉ុន្តែ តាមវិធីមួយម៉ឺងម៉ាត់។

ក. យ៉ូហាន ១៧ | មូលដ្ឋានខាងទេវសាស្ត្រសម្រាប់ការប្រកបគ្នា គឺចេញមកពីព្រះត្រីឯកផ្ទាល់ ដែលនោះជាសហគមន៍**ទីមួយ**។

ខ. ទំនុកតម្កើង ១៣៣ | នៅក្នុងសញ្ញាចាស់ យើងឃើញតម្លៃមួយដែលបានរៀបរាប់ប្រាប់ពីការរួបរួមនៅក្នុងចំណោមពួកអ្នកជឿ។

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- ព័ន្ធកិច្ចនៃក្រុមជំនុំរបស់យើង ជួយសមាជិកឲ្យលូតលាស់នៅក្នុងទំនាក់ទំនងជាមិត្តភាពជាមួយគ្នា។

1 2 3 4 5 6 7 8 9 10

- ការប្រកបគ្នាជាវិជ្ជមានមួយនៅក្នុងក្រុមជំនុំរបស់យើង។

1 2 3 4 5 6 7 8 9 10

នៅក្នុងពិភពលោក ដែលពេញដោយភាពកណ្តោចកណ្តែង ភាពឯកកោ ការបែកបាក់ និងហឹង្សា ការប្រកបគឺជាអាជ្ញាបញ្ញាដែលក្រុមជំនុំត្រូវធ្វើជាសហគមន៍មួយដែលផ្តល់នូវសេចក្តីស្រឡាញ់ ការផ្សះផ្សារ ព្រះគុណ និងការអត់ទោស។

សុំឲ្យសិក្ខាកាមបង្ហាញវិធីផ្សេងៗទៀតដែលធ្វើឲ្យសមាជិកអាចស្គាល់គ្នា និងជួយគ្នាទៅវិញទៅមក។

**របៀបដែលអ្នកដឹកនាំអាចនិយាយអំពីទំនាស់នៅក្នុងក្រុមជំនុំ |**

**១.** ស្គាល់ទំនាស់ (អ្វីដែលមនុស្សមិនឯកភាពគ្នា)

**២.** វិភាគទំនាស់នោះ ឲ្យបានដិតដល់តាមដែលអាចធ្វើទៅបាន គឺរកហេតុផលរបស់វា ជាអំពើដែលធ្វើឲ្យទំនាស់នោះចេះតែកើនឡើង។ល។ កុំបណ្តោយឲ្យមនុស្សវាយប្រហារគ្នាដោយពាក្យសម្តី តែសូមផ្តោតទៅលើអំពើដែលគេប្រព្រឹត្ត កុំផ្តោតលើមនុស្ស។

**៣.** រកឲ្យឃើញអ្វីដែលជាចំណុចរួមរបស់ភាគីទំនាស់។

**៤.** រកឲ្យឃើញវិធីដែលទំនាស់នោះអាចដោះស្រាយបាន។

**៥.** ជ្រើសរើសវិធីដែលស្មោះត្រង់បំផុតចំពោះបទបញ្ជារបស់ព្រះ នៅក្នុងបទគម្ពីរ ស្មោះត្រង់បំផុតចំពោះនិមិត្ត និងបេសកកម្មរបស់ក្រុមជំនុំ ព្រមទាំងសមរម្យបំផុត សម្រាប់ស្ថានភាពមនោះ។

**៦.** អញ្ជើញមនុស្សមកសាកសួរ ហើយផ្តល់ការអត់ទោស។

**៧.** អនុវត្តការសម្រេចចិត្ត។

### ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

- តើបងប្អូនប្រុសស្រីក្នុងព្រះគ្រិស្ត ក្នុងក្រុមជំនុំរបស់យើងស្គាល់គ្នាបានកម្រិតណា?
- តើលោកអ្នកឃើញពួកគេជួយគ្នា និងលើកទឹកចិត្តគ្នាដូចម្ដេច?
- តើក្រុមជំនុំរបស់យើងមានផែនការដោះស្រាយទំនាស់ឬទេ?
- តើអ្វីទៅជាទំនាស់ធ្ងន់ធ្ងរចុងក្រោយនៅក្នុងក្រុមជំនុំរបស់យើង ហើយទំនាស់នោះត្រូវបានដោះស្រាយដូចម្ដេច?

**៤. ការថ្វាយបង្គំ** | កិច្ចការ ២:៤២,៤៧; ទំនុកតម្កើង ៤៧:១; ទំនុកតម្កើង ៤៨:៩ រ៉ូម ១២:១-២

ក្រុមជំនុំជួបជុំគ្នាក្នុងភាពជាគ្រួសាររបស់ព្រះ ដើម្បីស្ដាប់ព្រះអង្គ ហើយឆ្លើយតបចំពោះព្រះអង្គជាការសរសើរ ការលន់តួ ការអរព្រះគុណ និងការទូលអង្វរ។ ក្នុងការថ្វាយបង្គំ យើងស្គាល់តេជានុភាពរបស់ព្រះ ហើយថ្វាយខ្លួនយើងចំពោះព្រះអង្គ។

កម្មវិធីថ្វាយបង្គំជាពេលមួយដ៏វិសេស ដែលប្រជារាស្ត្ររបស់ព្រះជួបជុំគ្នាជួបជាមួយព្រះអង្គទាំងអស់គ្នា។ នេះជាការជួបគ្នាដ៏វិសេសមួយ ដែលព្រះជាម្ចាស់មានបន្ទូលមកកាន់ប្រជារាស្ត្ររបស់ព្រះអង្គ ហើយប្រជារាស្ត្ររបស់ព្រះអង្គនិយាយទៅកាន់ព្រះអង្គ:

- ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យថ្វាយបង្គំព្រះអង្គ - យើងឆ្លើយតបដោយការសរសើរតម្កើងព្រះអង្គទាំងអស់គ្នា។
- ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យលន់តួអំពើបាប - យើងឆ្លើយតបដោយការលន់តួអំពើបាបរបស់យើង និងសុំការអត់ទោស - ព្រះជាម្ចាស់អត់ទោសយើង តាមរយៈព្រះយេស៊ូគ្រិស្ត។
- ព្រះជាម្ចាស់មានបន្ទូលមកកាន់យើងតាមរយៈព្រះបន្ទូលរបស់ព្រះអង្គ - យើងឆ្លើយតបដោយការប្រកាសជំនឿ ការថ្វាយតង្វាយ ទីបន្ទាល់ និងទូលពីសំណូមរបស់យើង។
- ព្រះជាម្ចាស់បង្ហាញសេចក្ដីស្រឡាញ់របស់ព្រះអង្គដល់យើង ដោយការញែកយើងជាបរិសុទ្ធ (ការជ្រមុជទឹក និងការលៀងព្រះអម្ចាស់) - យើងទទួលកិច្ចការរបស់ព្រះ តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ។
- ព្រះជាម្ចាស់ប្រទានពរយើង ហើយចាត់យើងឲ្យចេញទៅក្នុងពិភពលោក - យើងចេញពីកន្លែងថ្វាយបង្គំ ទាំងរួចរាល់ក្នុងការបម្រើព្រះ នៅក្នុងកិច្ចការប្រចាំជីវិតរបស់យើង។ ខដំបូងនៃគម្ពីររ៉ូម ១២ បង្ហាញថា ការថ្វាយបង្គំជានិយទូលាយ គឺពាក់ព័ន្ធនឹងគ្រប់ផ្នែកទាំងអស់នៃជីវិត។ យើងរស់នៅរាល់ថ្ងៃក្នុងវត្តមានរបស់ព្រះ ដោយឆ្លើយតបទៅនឹងសេចក្ដីសប្បុរស និងតេជានុភាពរបស់ព្រះអង្គ។

### កត្តាថ្វាយបង្គំដែលអាចជួយក្រុមជំនុំឲ្យល្អគួរលាស់

**១.** ការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះភ្ញៀវ (ត្រូវឲ្យប្រាកដថា ភ្ញៀវមានកន្លែងអង្គុយ ឬឈរ ហើយពន្យល់ដើម្បីឲ្យគេដឹងថា មានអ្វីកើតឡើង)។

**២.** ទំនាក់ទំនងជាមួយភ្ញៀវ (ត្រូវមានទំនាក់ទំនងផ្ទាល់ភ្លាមៗ ក្រោយពីគេបានចូលរួមថ្វាយបង្គំ)។

**៣.** បន្ទាប់សម្រាប់មនុស្សថ្មីៗ នៅក្នុងបរិវេណថ្វាយបង្គំ។

**៤.** ការអធិប្បាយត្រឹមត្រូវតាមព្រះគម្ពីរ ស្មោះត្រង់ទៅនឹងបទគម្ពីរ ហើយទាក់ទងទៅនឹងជីវិតរបស់មនុស្ស។

**៥.** ជូនពត៌មានច្បាស់ៗ អំពីរបៀបដែលមនុស្សអាចមានចំណែកនៅក្នុងក្រុមជំនុំ។

**លំហាត់** | ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក

- ការថ្វាយបង្គំនៅក្នុងក្រុមជំនុំរបស់យើង ធ្វើឲ្យយើងស្រស់បស់ ហើយចម្រើនកម្លាំងយើងសម្រាប់ជីវិតជាគ្រិស្តបរិស័ទ។

1 2 3 4 5 6 7 8 9 10

- នៅក្នុងកម្មវិធីថ្វាយបង្គំរបស់យើង បានបង្ហាញឲ្យមនុស្សស្គាល់ព្រះត្រីឯក គឺ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។

1 2 3 4 5 6 7 8 9 10

## ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

- តើការថ្វាយបង្គំរបស់យើង មានទាំងការលើកតម្កើង មានទាំងអំណរឬទេ?
- តើយើងប្រើសិល្បៈដើម្បីសិរីរុងរឿងរបស់ព្រះឬទេ?
- តើយើងសង្កត់ធ្ងន់ពេកតែទៅលើចំណុចណាមួយឬ? (គិតតែពីតន្ត្រី ឬសម្រាប់តែពួកអ្នកដឹក។ល។)

**វិភាគ | កិច្ចការប្រាំ**
ក្រោយពីសិក្ខាកាមបំពេញតារាងរួច សុំឲ្យពួកគេរកឲ្យឃើញកិច្ចការណាមួយ ក្នុងចំណោមកិច្ចការទាំងប្រាំ ដែលក្រុមជំនុំរបស់គេខ្លាំង និងចំណុចណា ដែលក្រុមជំនុំរបស់គេខ្សោយ។ សុំឲ្យពួកគេចែកចាយប្រាប់ដៃគូ ឬក្រុមនីមួយៗ ដែលមានគ្នា ៣-៤ នាក់។ ប្រសិនបើមានពេល សុំឲ្យសិក្ខាកាមចែកចាយប្រាប់គំនិត អំពីរបៀបកែលម្អចំណុចណា ដែលខ្សោយ។

មានកត្តាសំខាន់ៗផ្សេងៗទៀត ក្នុងការលូតលាស់របស់ក្រុមជំនុំ ដែលពួកអ្នកដឹកនាំត្រូវទទួលយកមកពិចារណា ដូចជារចនាសម្ព័ន្ធកម្មវិធី និងការប្រាស្រ័យទាក់ទង ព្រមទាំងសហគមន៍ និងបរិបទខាងវិញ្ញាណ ដែលក្រុមជំនុំរកឃើញដោយខ្លួនឯង។ យើងនឹងបកស្រាយចំណុចទាំងនេះ នៅក្នុងមេរៀនទី៤។

## វិភាគ | កិច្ចការទាំងប្រាំ

សម្រាប់កិច្ចការនីមួយៗ សូមចង្អុលបង្ហាញអំពីព័ន្ធកិច្ចនៅក្នុងក្រុមជំនុំលោកអ្នកៈ

| ការប្រកាសដំណឹងល្អ | ការបង្កើតសិស្ស | ការបម្រើ | ការប្រកបគ្នា | ការថ្វាយបង្គំ |
| --- | --- | --- | --- | --- |
| | | | | |

**១.** ក្រោយពីបានបំពេញតារាងរួចហើយ តើលោកអ្នកសម្គាល់ឃើញចំណុចខ្លាំង និងចំណុចខ្សោយឬទេ?

**២.** តើតារាងនេះបង្ហាញឲ្យឃើញមានតុល្យភាពបង្គួរចំពោះព័ន្ធកិច្ចឬទេ?

មេរៀនទី៨ |

# ប្រព័ន្ធផ្លាស់ប្រែ

## សេចក្តីផ្តើម

សង្គមវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ បានឲ្យយើងដឹងថា សរីរាង្គ (អ្វីៗដែលមានជីវិត) មានលក្ខណៈជាប្រព័ន្ធ គឺជីវិតទាំងមូលមានផ្នែកជាច្រើនដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកនៅក្នុងសរីរាង្គនោះ ហើយជាមួយនឹងអ្វីៗដែលស្ថិតនៅខាងក្រៅសរីរាង្គ។ ការយល់ដឹងអំពីរបៀបដែលប្រព័ន្ធដំណើរនេះ អាចយកមកអនុវត្តបានសម្រាប់អង្គភាពឯទៀតៗ។

ក្រុមជំនុំជាសរីរាង្គដ៏រស់ ជារូបកាយរបស់ព្រះគ្រិស្ត និងជាអង្គភាពមួយ។ ក្រុមជំនុំជារាងកាយមួយសាំញ៉ាំ និងមានប្រព័ន្ធផ្សំផ្សេងៗគ្នា ហើយវាមានទំនាក់ទំនងជាមួយបរិយាកាសដោយឡែកមួយ។ មានការពឹងផ្អែកគ្នាទៅវិញទៅមក និងមានឥទ្ធិពលចំពោះគ្នាទៅវិញទៅមកក្នុងចំណោមប្រព័ន្ធផ្សំទាំងអស់ ហើយបង្កើតបានជាប្រព័ន្ធមួយធំ។ ប្រព័ន្ធធំនេះក៏បញ្ចេញសកម្មភាព ហើយមានប្រតិកម្មជាមួយប្រព័ន្ធដទៃៗទៀត និងបរិយាកាសរបស់ខ្លួន។ ដោយការមើលឃើញរូបភាពធំនេះ អំពីទំនាក់ទំនងទៅវិញទៅមក និងឥទ្ធិពលទៅវិញទៅមកជាមួយនឹងបរិបទ ជាទស្សនៈវិស័យមួយដែលគេហៅថា «ប្រព័ន្ធចំហ»។ គោលគំនិតនេះ ជួយយើងឲ្យរកឃើញវិធីសាមញ្ញ ប្រកបដោយសុខភាពល្អ ដើម្បីរ៉ាប់រង និងបន្តកិច្ចការ «បង្កើតសិស្ស» ហើយធ្វើការផ្លាស់ប្តូរដែលចាំបាច់ ក្នុងនាមជាក្រុមជំនុំមួយដែលផ្តោតលើបេសកកម្ម។



លោកអ្នកត្រូវមើលដើមឈើ និងព្រៃផងដែរ។

**គោលការណ៍** | ក្រុមជំនុំជាសរីរាង្គមួយដែលមានជីវិត ជារូបកាយរបស់ព្រះគ្រិស្ត ហើយនៅពេលជាមួយគ្នានោះ ក្រុមជំនុំតាំងឡើងជាអង្គភាពដែលរឹងមាំ ហើយមើលឃើញនឹងភ្នែក (ក្រុមជំនុំ និកាយ) ដែលព្រះជាម្ចាស់ធ្វើការតាមរយៈក្រុមជំនុំនេះ នៅក្នុងពិភពលោក។ របៀបដែលយើងយល់ដឹងកាន់តែច្រើន អំពីអង្គការមួយដំណើរការជាយ៉ាងណា នោះយើងក៏អាចជួយក្រុមជំនុំរបស់យើងឲ្យបំពេញតួនាទីបាន កាន់តែប្រសើរឡើងយ៉ាងនោះដែរ។

ឧទាហរណ៍អំពីព្រៃ និងដើមឈើ គូសបញ្ជាក់ការពិតនេះ ដើម្បីបម្រើបានល្អ គឺអ្នកដឹកនាំក្រុមជំនុំត្រូវតែយល់ មិនត្រឹមផ្នែកមួយនៃព័ន្ធកិច្ចប៉ុណ្ណោះទេ (ដើមឈើ) គឺព័ន្ធកិច្ចទាំងមូល (ព្រៃ)។

**លំហាត់** | លេខបំភាន់ភ្នែក

លោកអ្នកមានពេល ៣០វិនាទី រកមើលលេខ ហើយគូសរង្វង់ជុំវិញលេខទាំងនោះ តាមលំដាប់លំដោយ (ចាប់ផ្ដើមពីលេខ១) ដើម្បីឲ្យដឹងថា លោកអ្នកអាចរកឃើញបានប៉ុន្មានលេខ។ រកឃើញលេខ១ គូសរង្វង់លើលេខ១ ឃើញលេខ២ គូសលេខ២ រួចបន្តទៅទៀត។

សូមសរសេរលេខខ្ពស់បំផុតដែលលោកអ្នកបានគូសរង្វង់: _______________



**រូបនេះបង្ហាញតម្លៃអំពី:**

- គំរូ
- សណ្ដាប់ធ្នាប់
- សមត្ថភាព
- ប្លង់
- ការយល់គម្រោងការរៀបចំ

**លំហាត់លេខបំភាន់ភ្នែក** | ធ្វើតាមការណែនាំដែលមាននៅក្នុងសៀវភៅសិក្ខាកាម។ ទុកឲ្យគេមានពេល ៣០វិនាទី ដើម្បីរកមើលលេខ និងគូសរង្វង់លើលេខទាំងនេះ ដោយចាប់ផ្ដើមពីលេខ១ ហើយមើលថា តើអាចរកបានប៉ុន្មានលេខ។ គេនឹងរកមើលលេខ១ គូសរង្វង់លើលេខ១ បន្ទាប់មក លេខ២ គូសលើលេខ២ លេខ៣ គូសលើលេខ៣ និងបន្តទៅទៀត រហូតទាល់តែអស់។ លុះគ្រប់ ៣០វិនាទី សុំឲ្យគេសរសេរលេខខ្ពស់បំផុតដែលរកបាន។

បន្ទាប់មក ធ្វើផ្នែកទីពីរនៃលំហាត់។ លើកនេះ ឲ្យគេធ្វើដូចមុន (គូររង្វង់លើលេខ ដើម្បីឲ្យដឹងថាគេរកបានលេខខ្ពស់ប៉ុនណា) ប៉ុន្តែ សូមផ្ដល់ឲ្យគេមានសញ្ញាពីរ មុននឹងគេចាប់ផ្ដើមគូសរង្វង់:

ក. លេខទាំងនោះត្រូវបានបែងចែកជាបួនចំណែក ។ លេខ ១-៦ មាននៅផ្នែកមួយចំហៀងខាងលើ និង៦លេខទៀត (៧-១២) មាននៅផ្នែកមួយចំហៀងខាងក្រោម ។ ៦លេខទៀត (១៣-១៨) មាននៅផ្នែកមួយចំហៀងខាងលើ និង៦លេខទៀត (១៩-២៣) មាននៅផ្នែកមួយចំហៀងខាងក្រោម និងមានត១ទៀត។
ខ. ជាមួយគ្នានេះដែរ មិនមានលេខតគ្នានៅក្នុងផ្នែកតែមួយនោះទេ។ ឧទាហរណ៍ លេខ ១-៦ នៅពាក់កណ្ដាលខាងលើនេះ ស្ថិតនៅឆ្លាស់គ្នាឆ្វេងស្ដាំ។

ក្រោយពីប្រាប់គេអំពីគំនិតទាំងពីរនេះរួច ចូរធ្វើលំហាត់នេះជាថ្មី ចំណាយពេល ៣០វិនាទី គូសរង្វង់លើលេខឲ្យបានច្រើនតាមដែលគេអាចធ្វើបាន។ អស់៣០វិនាទី សុំឲ្យគេលើកដៃឡើង ប្រសិនបើគេគូសបានលេខខ្ពស់ជាងមុននៅលើកទីពីរនេះ។ សួរសិក្ខាកាមពីមូលហេតុដែលគូសបានលេខខ្ពស់ជាងមុននៅលើកទីពីរនេះ។ ពួកគេអាចនិយាយថា មកពីលើកទីពីរនេះ គេយល់ច្បាស់ពីប្រព័ន្ធ ឬគេដឹងអំពីរបៀបដែលលេខទាំងនោះ ត្រូវបានគេរៀបចំទុក។ល។

គោលបំណងលំហាត់នេះបង្ហាញពីតម្លៃនៃការយល់ដឹងអំពីរបៀបដែលប្រព័ន្ធមួយត្រូវបានគេរៀបចំ។ តាមវិធីតែមួយនេះ ការយល់ដឹងពីថាមពលនៃរបៀបដែលក្រុមជំនុំលូតលាស់ អាចជួយយើងឲ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងព័ន្ធកិច្ចដែលព្រះបានប្រទានមកយើង។

# សមាសភាពនៃអង្គភាពមួយ

## **ដ្យាក្រាមទី១** | កត្តាខាងក្រៅដែលជះឥទ្ធិពលដល់ក្រុមជំនុំ

**សហគមន៍ | បរិយាកាស**

ទំនៀមទម្លាប់សាសនា | តម្លៃស្របតាមព្រះគម្ពីរ




ប្រវត្តិអង្គភាព

**តម្លៃស្នូលនៃព័ន្ធកិច្ច**

- កត្តាខាងក្រៅខ្លះដែលអាចពិភាក្សា និងបត់បែនបាន
- កត្តាខាងក្រៅខ្លះដែលមិនអាចពិភាក្សាបាន គឺនៅនឹងមួយកន្លែង។

### សកម្មភាព:

សូមលើកឧទាហរណ៍អំពីកត្តាខាងក្រៅដែលជះឥទ្ធិពលដល់ក្រុមជំនុំលោកអ្នក។ តើកត្តានោះអាចពិភាក្សាបាន ឬនៅនឹងមួយកន្លែង?

### ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

- រកឲ្យឃើញកត្តាខាងក្រៅខ្លះដែលជះឥទ្ធិពល ហើយឆ្ពៃក្រុមជំនុំរបស់លោកអ្នក។ តើមួយណាអាចពិភាក្សាបានច្រើនជាង? តើមួយណាដែលមិនសូវនៅនឹងមួយកន្លែង?

**សមាសភាពនៃអង្គភាពមួយ** | ព្រំដែន/ដែនកំណត់

ទាំងនេះជាព្រំដែនខាងក្រៅនៃសរីរាង្គ ដែលខុសប្លែកពីសរីរាង្គដទៃៗទៀត។ តម្លៃស្របតាមព្រះគម្ពីរ ទំនៀមទម្លាប់សាសនា ប្រវត្តិ និងតម្លៃអង្គភាពរបស់យើង កំណត់ឲ្យដឹងថាយើងជានរណា ហើយយើងនឹងធ្វើអ្វី។

ឧទាហរណ៍: ក្រុមជំនុំដែលមានសុខភាពល្អនឹងធ្វើតាមដែនកំណត់នៅក្នុងព្រះគម្ពីរ និងមិនអនុញ្ញាតឲ្យសមាជិករបស់ខ្លួននិយាយដើមគេ (លេវី ១០:១៦ ទំនុក ៣៤:១៣ យ៉ាកុប ៤:១១)។ ដែនកំណត់ក៏រាប់ទាំងព្រំដែនខាងសាច់ឈាមដែរ។ ដូចជាអាគារក្រុមជំនុំ និងធនធានក្រុមជំនុំ។

- ព្រំដែនខ្លះអាចពិភាក្សា និងបត់បែនបាន។ សកម្មភាពខាងវប្បធម៌ និងទម្លាប់ក្រុមជំនុំអាចប្រែប្រួល។ ទំនៀមទម្លាប់សាសនាវិវឌ្ឍតាមវិធីផ្សេងៗ ហើយតម្លៃអាចប្រែប្រួល នៅពេលយើងកាន់តែលូតលាស់ ស្របនឹងអ្វីដែលព្រះត្រាស់ហៅយើងឲ្យធ្វើ។
- ព្រំដែនខ្លះមិនអាចពិភាក្សាបានទេ គឺនៅនឹង។ ឧទាហរណ៍: បញ្ញត្តិនៅក្នុងព្រះគម្ពីរ។

**បរិបទ** | គ្រប់សរីរាង្គទាំងអស់ មានរូបរាងនៅក្នុងស្ថានភាពមួយ។ ក្រុមជំនុំនីមួយៗ រកឃើញខ្លួនឯងនៅក្នុងកន្លែងមួយជាក់លាក់ នៅក្នុងចំណុច និងពេលវេលាមួយច្បាស់លាស់។ ការយល់ដឹងអំពីមជ្ឈដ្ឋានជុំវិញ (វប្បធម៌ ការរស់នៅរបស់មនុស្ស។ល។) អាចជួយយើងឲ្យប្រកាសដំណឹងល្អ តាមរបៀបដែលកាន់តែមានប្រសិទ្ធភាព។

**សកម្មភាពថែទាំ** | ឲ្យអ្នកដឹកនាំក្រុមជំនុំលោកអ្នក រៀបរាប់អំពីអ្វីៗដែលគេយល់ដឹងអំពីមនុស្សដែលនៅជិតខាងលោកអ្នក (ចំណាប់អារម្មណ៍ និងសេចក្តីត្រូវការរបស់គេ។ល។) សាកសួរអ្នកជិតខាង ដើម្បីស្វែងយល់អំពីពួកគេថែមទៀត និងអ្វីដែលគេយល់ដឹងអំពីក្រុមជំនុំ។

**កំណត់ចំណាំ** | នេះជាផ្នែកបច្ចេកទេសបំផុតនៃវគ្គសិក្ខាសាលាទាំងមូល។ ប្រសិនបើលោកអ្នកយល់មិនច្បាស់អំពីដ្យាក្រាម ឬគិតថា ដ្យាក្រាមទាំងនេះគ្មានប្រយោជន៍សម្រាប់សិក្ខាកាមលោកអ្នក សូមងាកទៅមើលលំហាត់ «កម្រាលព្រំក្រហម» នៅទំព័រ២៨ ក្នុងសៀវភៅសិក្ខាកាម។

**គោលគំនិតសំខាន់ៗនៃប្រព័ន្ធមួយ** | អង្គភាពមួយមានទាំងសមាសភាពខាងក្រៅ និងខាងក្នុង។ សូមរំឭកសិក្ខាកាមថា ក្រុមជំនុំដែលជាស្ថាប័ន ជាអង្គភាពមួយមើលឃើញនឹងភ្នែក ដែលព្យាយាមបំផ្លាស់បំប្រែមនុស្ស និងសហគមន៍សម្រាប់សិរីរុងរឿងរបស់ព្រះ និងការលូតលាស់នៃក្រុមជំនុំរបស់ព្រះយេស៊ូគ្រិស្ត។

នៅខាងក្រោមនេះ ជាការពណ៌នាអំពីសមាសភាពនៃអង្គភាពមួយ និងអំពីគោលគំនិតសំខាន់ៗនៃប្រព័ន្ធមួយដែលរៀបរាប់នៅក្នុងសៀវភៅសិក្ខាកាម។ សូមពន្យល់សមាសភាព និងគោលគំនិតទាំងនេះ ដោយភ្ជាប់ទៅនឹងដ្យាក្រាមទាំងបីនៅទំព័រ ២៥-២៧ ក្នុងសៀវភៅសិក្ខាកាម។ សូមប្រើឧទាហរណ៍ផ្ទាល់ខ្លួន ដើម្បីជួយពន្យល់អំពីសមាសភាព និងគោលគំនិតទាំងនោះ។

**សមាសភាពខាងក្នុង** | ក្រុមជំនុំ ក៏ដូចជាអង្គការដែរ មានផ្នែកច្រើនដែលមានឥទ្ធិពលលើរបៀបដំណើរការរបស់ខ្លួន។ អ្នកដឹកនាំ កម្មវិធី សមាជិក និងធនធាន សុទ្ធតែមានឥទ្ធិពល ទាំងវិជ្ជមាន និងអវិជ្ជមាន។

ក្រុមជំនុំស្ថិតនៅក្រោមសិទ្ធអំណាចដឹកនាំរបស់ព្រះគ្រិស្ត ហើយគោលបំណងនៃភាពដឹកនាំនេះ គឺប្រកាស និងរស់នៅតាមដំណឹងល្អ តាមរបៀបមួយដែលអ្នកដទៃអាចស្គាល់ព្រះគ្រិស្ត ជាព្រះអម្ចាស់។ នៅក្នុងក្រុមជំនុំមានប្រព័ន្ធផ្សេងៗ ដូចជាថ្នាក់ដឹកនាំ រចនាសម្ព័ន្ធក្រុមជំនុំ សមាជិក កម្មវិធី ខ្លឹមសារនៃការប្រកាសព័ត៌មាន និងការប្រើប្រាស់ធនធាន។ នៅពេលដែលប្រព័ន្ធផ្សំទាំងនេះត្រូវបានដឹកនាំឆ្ពោះទៅរកបេសកកម្មក្រុមជំនុំ ហើយដំណើរការបានល្អ នោះជីវិតរបស់មនុស្ស ព្រមទាំងសហគមន៍នឹងត្រូវបានផ្លាស់ប្រែ ដោយអំណាចនៃដំណឹងល្អ។ នៅពេលដែលមានអ្វីមួយមិនស្រួលនៅក្នុងប្រព័ន្ធផ្សំណាមួយ នោះប្រព័ន្ធផ្សំផ្សេងទៀតក៏ទទួលរងឥទ្ធិពលដែរ។ នេះដោយព្រោះតែប្រព័ន្ធផ្សំមានទំនាក់ទំនងគ្នា និងពឹងផ្អែកគ្នាទៅវិញទៅមក។

## ដ្យាក្រាមទី២ | សមាសភាពខាងក្នុងនៃក្រុមជំនុំ

**ក្រុមជំនុំដែលមានព្រះគ្រិស្តជាសិរសា**

សរីរាង្គ | អង្គភាព




លំហូរមនុស្ស | ការស្វាគមន៍ - ការរួមចំណែក - ព័ន្ធកិច្ច

- ក្នុងក្រុមជំនុំនីមួយៗ មានប្រព័ន្ធផ្សំដែលមានឥទ្ធិពលទៅលើរបៀបដែលក្រុមជំនុំដំណើរការ។

## សកម្មភាព:

កំណត់ប្រព័ន្ធផ្សំមួយចំនួននៃក្រុមជំនុំរបស់លោកអ្នក (កម្មវិធី ព័ន្ធកិច្ច គណៈកម្មការ។ល។) តើប្រព័ន្ធទាំងនេះមានទំនាក់ទំនងនឹងគ្នាដូចម្ដេច?

____________________________________________

____________________________________________

____________________________________________

____________________________________________

## ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

- រកឲ្យឃើញផ្នែកផ្សេងៗគ្នានៃក្រុមជំនុំរបស់លោកអ្នក និងព្រះពរ ព្រមទាំងចំណុចប្រឈមនៃផ្នែកនីមួយៗ។

**ការរួមបញ្ចូលគ្នា និងការពឹងផ្អែកគ្នាទៅវិញទៅមក** | គ្រប់ផ្នែកនៃប្រព័ន្ធមួយ សុទ្ធតែមានការតភ្ជាប់គ្នាទៅវិញទៅមក និងមានឥទ្ធិពលដល់គ្នាទៅវិញទៅមក។ នៅក្នុងក្រុមជំនុំមួយ នៅពេលមានបញ្ហាមួយកើតឡើងក្នុងចំណុចណាមួយនៃជីវិតរបស់ក្រុមជំនុំ ចំណុចនោះមានផលប៉ះពាល់ដល់ផ្នែកផ្សេងៗទៀត។ ឧ. បញ្ហាថវិកាអាចមានន័យថា ជាចំណុចប្រឈមសម្រាប់កម្មវិធីផ្សេងទៀត ខណៈដែលសមាជិកកាន់តែច្រើន ប្រើអំណោយទានរបស់ខ្លួន អាចជាព្រះពរដល់កម្មវិធីរបស់ក្រុមជំនុំ។

**គោលបំណង** | ប្រព័ន្ធនីមួយៗមានគោលបំណងជាក់លាក់។ គោលបំណងរបស់ក្រុមជំនុំ ត្រូវបានកំណត់ដោយអ្វីដែលព្រះជាម្ចាស់បង្រៀននៅក្នុងបទគម្ពីរ ពោលគឺ ប្រកាសដំណឹងល្អអំពីជីវិតក្នុងព្រះគ្រិស្ត និងបង្រៀនមនុស្សឲ្យរស់នៅតាមព្រះហឫទ័យរបស់ព្រះ (ម៉ាថាយ ២៨:១៩-២០)។ នៅពេលដែលក្រុមជំនុំធ្វេសប្រហែសនឹងបេសកកម្មបង្កើតសិស្ស ក្រុមជំនុំរស់នៅមិនត្រូវតាមគំរូរបស់ព្រះទេ។

**ស្ថិរភាព និងការថែរក្សាលំនឹង** | ប្រព័ន្ធទាំងអស់ច្រើនតែប្រឆាំងនឹងការផ្លាស់ប្ដូរ។ នៅក្នុងក្រុមជំនុំ យើងតែងឮមនុស្សមិនទទួលយកគំនិតថ្មី ព្រោះ «យើងមិនធ្លាប់ធ្វើតាមរបៀបនោះពីមុនមក»។ មនុស្សចូលចិត្តធ្វើអ្វីៗតាមរបៀបដដែលៗ ជាជាងរៀនរបៀបថ្មី។ ពួកអ្នកដឹកនាំ ត្រូវរកវិធីជួយសមាជិកឲ្យយល់ពីការផ្លាស់ប្ដូរ និងមើលឃើញមូលហេតុដែលនៅពីក្រោយ ហើយត្រូវឲ្យប្រាកដថា អត្រានៃការផ្លាស់ប្ដូរសមហេតុផល។

**សម្រេចបានគោលដៅដូចគ្នា** | មានវិធីសាស្ត្រច្រើនដើម្បីសម្រេចគោលដៅតែមួយដូចគ្នា។ ការនេះអនុញ្ញាតឲ្យប្រព័ន្ធនានាមានការបត់បែនបាន ហើយធ្វើការកែតម្រូវ។ ឧ. ក្រុមជំនុំមួយគ្មានលទ្ធភាពនឹងទិញសម្ភារៈផ្សេងៗដើម្បីជួយស្ត្រីមេម៉ាយកូនច្រើន ដែលរស់នៅក្បែរខាង ប៉ុន្តែអាចមានអ្នកខ្លះអាចជួយមើលកូន ក្រោយពីពួកគេចេញពីសាលា នៅពេលម្ដាយជាប់រវល់នឹងការងារ។

**ផែនការបម្រុង** | អង្គភាពខ្លះបំពេញតួនាទីក្នុងបរិយាកាសដែលមិនបានគិតទុក ដូច្នេះ គេត្រូវតែអាចធ្វើផែនការបម្រុង ជាផែនការដែលអាចយកជាការបាន នៅពេលដែលផែនការមេបរាជ័យ។ ប្រព័ន្ធមួយដែលមានសុខភាពល្អ ត្រូវមានផែនការដែលអាចផ្លាស់ប្ដូរបាន ដើម្បីឲ្យផែនការនោះអាចនៅតែសម្រេចបានគោលដៅរបស់ខ្លួន នៅពេលដែលមានអ្វីមួយមិនប្រក្រតី។ ឧ. ក្រុមជំនុំមួយ មានផែនការលើកយុទ្ធនាការប្រកាសដំណឹងល្អនៅតាមទីសាធារណៈ ហើយរឿងដែលឈ្លាសវៃ គឺត្រូវមាន «ផែនការខ» ក្នុងករណីមានភ្លៀង។

## **ដ្យាក្រាមទី៣** | សមាសភាពខាងក្រៅ និងខាងក្នុង - ការបំផ្លាស់បំប្រែ




- ការបំផ្លាស់បំប្រែវិជ្ជមាននៅក្នុងក្រុមជំនុំ និងនៅក្នុងសហគមន៍ កើតឡើងនៅពេលដែលផ្នែកខាងក្នុងរបស់ក្រុមជំនុំ បម្រើបេសកកម្មក្រុមជំនុំ ទៅតាមរបៀបមួយដែលសមស្របទៅនឹងបរិបទ។
- ការបំផ្លាស់បំប្រែវិជ្ជមានត្រូវអន់ថយ ឬឈប់ នៅពេលដែលផ្នែកខាងក្នុងរបស់ក្រុមជំនុំ មិនបែរតម្រង់ទៅរកនិមិត្ត និងបេសកកម្មរបស់ខ្លួន។

## គោលគំនិតសំខាន់ៗនៃប្រព័ន្ធនានា

- បរិបទ
- ការរួមបញ្ចូលគ្នា និងពឹងផ្អែកគ្នា
- គោលបំណង
- ស្ថិរភាព និងរក្សាលំនឹង[1]
- សម្រេចបានគោលដៅដូចគ្នា[2]
- ផែនការបម្រុង[3]
- គម្រោង និងដែនកំណត់

ក្រុមជំនុំសុខភាពល្អ ត្រូវមានវិធីច្រើនក្នុងការស្វាគមន៍មនុស្សថ្មីៗ ដាក់ឲ្យគេមានចំណែក ថែបំប៉នគេក្នុងជំនឿ ហើយឲ្យគេចាប់ផ្តើមប្រើអំណោយទានរបស់ខ្លួន។

ក្រុមជំនុំសុខភាពល្អ ហើយលូតលាស់ ជានិច្ចកាលត្រូវពិនិត្យផ្នែកផ្សេងៗទៀតនៃប្រព័ន្ធរបស់ខ្លួន។ គេត្រូវដឹងច្រើនថែមទៀតអំពីបរិបទរបស់ខ្លួន វាយតម្លៃអំពីរៀបដែលកម្មវិធីដំណើរការ ត្រួតពិនិត្យមើលដើម្បីឲ្យប្រាកដថា ធនធាននានាប្រើប្រាស់បានល្អ។ល។

[1] សមត្ថភាពនៃសរីរាង្គមួយ រៀបរយបរិយាកាសខាងក្នុងរបស់ខ្លួន ដើម្បីរក្សាភាពមួយជាក់លាក់។

[2] សមត្ថភាពសម្រេចបានលទ្ធផលដូចគ្នា តាមរយៈមធ្យោបាយផ្សេងៗគ្នា។

[3] ផែនការដែលអាចអនុវត្តបាន នៅពេលផែនការមេបរាជ័យ។

**ការបំផ្លាស់បំប្រែ** | ប្រព័ន្ធនីមួយៗបម្រើឲ្យគោលបំណងមួយជាក់លាក់។ គោលបំណងរបស់ក្រុមជំនុំ គឺនាំមនុស្សមកជួបជាមួយព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គបំផ្លាស់បំប្រែជីវិត និងសហគមន៍របស់គេ។

រូបដ្យាក្រាមនេះ បង្ហាញអំពីសមាសភាពទាំងខាងក្នុង និងខាងក្រៅ នៅក្នុងរូបភាពមួយ។

- តើអាចមានអ្វីកើតឡើង ប្រសិនបើមានមនុស្ស ៥, ១០ ឬ ២០គ្រួសារ ចូលរួមក្រុមជំនុំលោកអ្នក?
- នៅក្នុងចំណោមមនុស្សថ្មីៗ ដែលមកព្រះវិហារ តើអាចមានអ្នកខ្លះមានអំណោយទានច្រៀង ឬដឹកនាំការថ្វាយបង្គំឬទេ?
- តើអស់អ្នកដែលចូលរួម ជាមនុស្សល្អ គួរឲ្យពេញចិត្តឬទេ?
- តើនឹងមានពីរបីនាក់ មានយោបល់មុតមាំឬទេ?
- តើនឹងមានពីរបីនាក់ មានបញ្ហាធ្ងន់ធ្ងរឬទេ?
- តើនឹងមានអ្នកខ្លះនិយាយដើមឬទេ?

សំណួរទាំងនេះ នឹងធ្វើឲ្យសិក្ខាកាមគិត អំពីដំណើរលូតលាស់ ដែលអាចជះឥទ្ធិពលលើក្រុមជំនុំបច្ចុប្បន្នរបស់គេ។ ក្រុមជំនុំដែលមានមនុស្ស ៨០នាក់ ហើយមានអ្នកថ្មីៗពី ២០-៣០ នាក់បន្ថែមជារៀងរាល់ឆ្នាំ នឹងជួបកម្រិតខ្ពស់នៃការផ្លាស់ប្តូរមួយខ្ពស់ ហើយមានផលប៉ះពាល់ទៅលើប្រព័ន្ធរបស់ខ្លួន។ នេះជារឿងសំខាន់ណាស់ដែលអ្នកដឹកនាំក្រុមជំនុំ ត្រូវរៀបចំខ្លួន ដើម្បីដោះស្រាយផលប៉ះពាល់នេះតាមរបៀបមួយល្អ ដែលអនុញ្ញាតឲ្យក្រុមជំនុំមានការលូតលាស់។ ពុំនោះទេ ចំនួនមនុស្សនឹងធ្លាក់ចុះ ហើយក្រុមជំនុំមិនលូតលាស់ឡើយ។ នេះជាឧទាហរណ៍ពីរ ដែលលោកអ្នកអាចប្រើ ដើម្បីបញ្ជាក់អំពីសារសំខាន់ នៃតុល្យភាពក្នុងការលូតលាស់របស់ក្រុមជំនុំ:

- ប្រសិនបើលោកអ្នកបន្ថែមអំបិល ទៅក្នុងសម្ល វានឹងផ្លាស់ប្តូររសជាតិ។ លោកអ្នកអាចថែមអំបិលកាន់តែច្រើន ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ លោកអ្នកក៏ត្រូវថែមទឹកឲ្យច្រើន បន្លែឲ្យច្រើន សាច់ឲ្យច្រើន និងគ្រឿងផ្សំផ្សេងទៀតផងដែរ ដើម្បីឲ្យរស់ជាតិមានតុល្យភាព។ លោកអ្នកមិនអាចគ្រាន់តែថែមអំបិលប៉ុណ្ណោះឡើយ។
- រូបកាយមនុស្ស ជាប្រព័ន្ធមួយដែលត្រូវការតុល្យភាពភាព ដើម្បីរក្សាសុខភាព។ បើបេះដូងលោកអ្នកល្អ តែថ្លើមមិនល្អ នោះមិនអាចជួយឲ្យមានបេះដូងខ្លាំងបាន ឡើយ។ លោកអ្នកត្រូវការឲ្យមានសរីរាង្គទាំងអស់ល្អ ទើបសុខភាពល្អ។

**លំហាត់ | កម្រាលព្រំក្រហម**

លំហាត់នេះ ជាផ្នែកសំខាន់បំផុតនៃមេរៀនទី៤។ បញ្ហាដែលបានពណ៌នា ត្រូវបង្កើតឲ្យមានការពិភាក្សា និងការសិក្សាច្រើន។ ចូរអានព័ត៌មាននៅក្នុងសៀវភៅសិក្ខាកាម ពន្យល់លំហាត់ បន្ទាប់មក បែងចែកសិក្ខាកាមជាក្រុមតូចៗ មានគ្នាពី ៥-៨នាក់ ឲ្យឆ្លើយទៅនឹងសំណួរ ដែលបានដាក់ជូន។ លំហាត់នេះ ត្រូវការពេលវេលាយ៉ាងតិច ពី ២០-៣០នាទី ដើម្បីបញ្ចប់។

ចំណុចសំខាន់នៃលំហាត់នេះ គឺឲ្យសិក្ខាកាមយល់អំពីភាពស្មុគស្មាញនៃការសម្រេចចិត្តពិតប្រាកដ នៅក្នុងព័ន្ធកិច្ចរបស់ក្រុមជំនុំ និងរបៀបដែលការផ្លាស់ប្ដូរមួយ អាចជះឥទ្ធិពលដល់ចំណុចផ្សេងៗទៀត នៃជីវិតក្រុមជំនុំ។ ការស្វែងរកដំណោះស្រាយសម្រាប់បញ្ហា មិនសំខាន់ណាស់ណាទេ ប៉ុន្ដែ សិក្ខាកាមត្រូវតែគិត អំពីភាពស្មុគស្មាញនៃបញ្ហាដែលមាននៅក្នុងក្រុមជំនុំ ដែលជាឥទ្ធិពលប្រកបដោយសក្ដានុពលនៃការសម្រេចចិត្តនីមួយៗ ទាក់ទងទៅនឹងផ្នែកផ្សេងៗនៃជីវិតក្រុមជំនុំ។

ពេលធ្វើលំហាត់នេះចប់ សុំឲ្យពីរក្រុម ឬបីក្រុម (ប្រសិនបើមានពេល) ចាត់មនុស្សឲ្យចែកចាយប្រាប់គ្រប់គ្នា អំពីចម្លើយនៃក្រុមរបស់គេ ដែលឆ្លើយទៅនឹងសំណួរនៅក្នុងសៀវភៅ និងអ្វីដែលក្រុមជំនុំរបស់គេធ្វើការសម្រេចចិត្ត ក្នុងករណីនេះ។

## ការថែទាំរបស់អ្នកដឹកនាំក្រុមជំនុំលោកអ្នក:

ពិភាក្សាអំពីរបៀបដែលផ្នែកផ្សេងទៀតនៃក្រុមជំនុំរបស់លោកអ្នកកំពុងធ្វើ និងចំណុចណាដែលលោកអ្នកចង់ដោះស្រាយៈ

- សុំឲ្យអ្នកដឹកនាំក្រុមជំនុំរបស់លោកអ្នក កត់ត្រារាល់អ្វីៗដែលពួកគេដឹង អំពីមនុស្សដែលនៅជិតខាងលោកអ្នក (ចំណាប់អារម្មណ៍របស់គេ សេចក្ដីត្រូវការរបស់គេ។ល។)
- សម្ភាសអ្នកជិតខាង ដើម្បីយល់ដឹងថែមទៀតអំពីពួកគេ និងអ្វីដែលគេគិតអំពីក្រុមជំនុំ។
- តើលោកអ្នកស្គាល់បរិបទរបស់ខ្លួនគ្រប់គ្រាន់ទេ?
- តើអ្នកដឹកនាំក្រុមជំនុំរបស់លោកអ្នកជូនព័ត៌មានច្បាស់ៗដល់ក្រុមជំនុំឬទេ?
- តើសមាជិករបស់លោកអ្នកប្រើអំណោយទានរបស់ខ្លួនឬទេ?
- តើព័ន្ធកិច្ចផ្ដោតទៅលើនិមិត្ត និងបេសកកម្មរបស់ក្រុមជំនុំ ឬក៏ផ្ដោតទៅលើគោលបំណងណាផ្សេងទៀត?

**លំហាត់** | «កម្រាលព្រំក្រហម»

ម្ភៃឆ្នាំមុន ក្រុមជំនុំ «Living Water» បានសម្ពោធអាគារព្រះវិហារថ្មីរបស់ខ្លួន។ គ្រូជំនួយម្នាក់ លោកម៉ៃឃើលស្មីត (Michael Smith) មានអាយុ ៦៧ឆ្នាំទៅហើយនៅពេលនោះ គាត់បានជួយជាប្រាក់សម្រាប់ទិញកម្រាលព្រំ ដែលមានពណ៌ក្រហម ដ្បិតពណ៌ក្រហមជាពណ៌ដែលគាត់ចូលចិត្ត។ មនុស្សគ្រប់គ្នាពេញចិត្តនឹងកាយវិការបស់លោកម៉ៃឃើល រួមទាំងគ្រួសាររបស់គាត់ដែរ ដែលធ្វើឲ្យគាត់មានឥទ្ធិពលនៅក្នុងក្រុមជំនុំ ហើយគេបានយកកម្រាលព្រំក្រហមនោះទៅក្រាល។

ម្ភៃឆ្នាំក្រោយមក គណៈកម្មារធិការអាគារព្រះវិហារ គិតផ្លាស់ប្ដូរកម្រាលព្រំ និងដាក់នៅជាន់ផ្សេងទៀត ដើម្បីឲ្យកន្លែងថ្វាយបង្គំអាចប្រើបានផងដែរសម្រាប់សកម្មភាពជាច្រើនទៀត នៅក្នុងមួយសប្ដាហ៍ (ដូចជាក្លឹបកុមារ ឬបម្រើអាហារដល់សហគមន៍ដោយឥតគិតថ្លៃ)។ ពួកគេគិតពីការប្រើប្រាស់ថវិកាដែលពួកគេបានរៃអង្គាសសម្រាប់កែលម្អអាគារឲ្យមានកម្រាលថ្មី។ ភ្លាមៗនោះ សមាជិកវ័យចំណាស់ គឺលោកម៉ៃឃើល បានផ្ដល់ជំនួយយ៉ាងសំខាន់សម្រាប់ការកែលម្អអាគារ ហើយបានសុំឲ្យទិញកម្រាលព្រំក្រហមម្ដងទៀត។ គ្រួសាររបស់គាត់បានយល់ព្រមនឹងសំណើរបស់គាត់ ប៉ុន្ដែ គណៈកម្មាធិការអាគារ ចង់ឲ្យជាន់នោះបម្រើបានគ្រប់គោលបំណង។

គ្រូគង្វាលមានចិត្តខ្វល់ខ្វាយ។ គាត់ដឹងមុនថា លោកម៉ៃឃើល និងគ្រួសាររបស់គាត់មានឥទ្ធិពលប៉ុណ្ណា ប៉ុន្ដែ គាត់ក៏បានផ្ដល់សិទ្ធិអំណាចឲ្យគណកម្មាធិការអាគា ធ្វើការផ្លាស់ប្ដូរកន្លែងថ្វាយបង្គំ ដែលមានប្រយោជន៍សម្រាប់ប្រើប្រាស់កម្មវិធីផ្សេងៗទៀតបាន។ ប៉ុន្ដែ គាត់សឹងតែមិនជឿថា មនុស្សទាស់ទែងគ្នាអំពីរឿងកម្រាលនេះ មានការចម្រូងចម្រាសមែនទែន នៅពេលដែលមានសេចក្ដីត្រូវការយ៉ាងធំនៅក្នុងសហគមន៍នោះ។ មានអ្នកខ្លះនៅក្នុងភាគីម្ខាងៗ បានគម្រាមនឹងចាកចេញពីក្រុមជំនុំ ប្រសិនបើការសម្រេចចិត្តមិនបានដូចចិត្តរបស់ពួកគេ:

ក. សាច់ញាតិរបស់លោកម៉ែខល ដែលមិនបានមកព្រះវិហារយូរមកហើយ បាននិយាយថា គាត់មិនត្រឡប់មកព្រះវិហារវិញទេ ប្រសិនបើគណៈកម្មាធិការមិនផ្ដល់កិត្តិយសចំពោះអំណោយ និងសំណើរបស់លោកម៉ែខល។

ខ. សមាជិកម្នាក់ធ្វើការយូរមកហើយនៅក្នុងព័ន្ធកិច្ចស្ត្រី ដែលបានប្រកាសដំណឹងល្អដល់មនុស្សនៅក្នុងសហគមន៍ បាននិយាយថា ប្រសិនបើគណៈកម្មាធិការដាក់បំណងរបស់មនុស្សម្នាក់ ខ្ពស់ជាងសេចក្ដីត្រូវការនៃព័ន្ធកិច្ចក្រុមជំនុំ គាត់ត្រូវតែរកព្រះវិហារផ្សេងទៀត។

គ. គ្រួសារមួយចំនួនដែលមានកូនតូចៗនិយាយថា ក្រុមជំនុំត្រូវតែចាប់អារម្មណ៍លើព័ន្ធកិច្ចរបស់ខ្លួនចំពោះកុមារ។

កាន់តែស្មុគស្មាញថែមទៀតនោះ គឺថាថ្មីៗនេះ លោកម៉ែខលស្ទីតឈឺ ហើយត្រូវវះកាត់បេះដូង។

គណៈកម្មាធិការបានអញ្ជើញពួកគ្រូគង្វាល មកចូលរួមប្រជុំជាមួយពួកគេនៅយប់នោះ ដើម្បីពិភាក្សាអំពីស្ថានភាព។

នៅក្នុងក្រុមដែលមានគ្នាពី ៣-៥នាក់ សូមស្រមៃថា លោកអ្នកជាគណៈកម្មាធិការ ហើយកំពុងតែប្រជុំជាមួយពួកគ្រូគង្វាល ដើម្បីពិភាក្សាអំពីស្ថានភាព។ សូមប្រើសំណួរទាំងនេះ ដើម្បីជួយលោកអ្នករិះរកមធ្យោបាយ ហើយចេញជាអនុសាសន៍មួយ:

១. តើស្ថានភាពនៅក្នុងក្រុមជំនុំនេះ មានផលប៉ះពាល់ដល់សហគមន៍ឬទេ? តើមានផលប៉ះពាល់ដូចម្ដេច?

២. តើស្ថានភាពនេះមានផលប៉ះពាល់ដល់ផ្នែកណាមួយនៃក្រុមជំនុំ ដូចបានរៀបរាប់ខាងក្រោមនេះឬទេ? តើមានផលប៉ះពាល់ដូចម្ដេច?

| | | |
|---|---|---|
| ទីតាំង | អ្នកដឹកនាំ | ប្រវត្តិអង្គភាព |
| និមិត្ត/គោលបំណង | សមាជិក | តម្លៃនៃក្រុមជំនុំ |
| ធនធាន | រចនាសម្ព័ន្ធ | ផ្នែកផ្សេងៗទៀត |
| កម្មវិធី | បរិយាកាស/ទំនាក់ទំនង | |

៣. ជម្រើសអ្វីខ្លះ ដែលក្រុមជំនុំមាន? តើអ្វីខ្លះជាលទ្ធផលដែលអាចកើតចេញពីជម្រើសនីមួយៗ?

៤. តើក្រុមជំនុំអាចសម្រេចចិត្តដូចម្ដេចឲ្យត្រូវទៅតាមនិមិត្ត និងបេសកកម្មរបស់ខ្លួនក្នុងពេលដែលពិចារណាអំពីប្រព័ន្ធទាំងមូល?

**សេចក្ដីសន្និដ្ឋាន**| នៅចុងបញ្ចប់នៃវគ្គសិក្ខាសាលា:

១. ឲ្យសិក្ខាកាមបំពេញទម្រង់វាយតម្លៃ។

២. ប្រសិនបើអាច សូមថតរូបសិក្ខាសាលារបស់លោកអ្នក ផ្ញើមកអង្គការ Multiplication Network។

៣. លើកទឹកចិត្តសិក្ខាកាម ឲ្យបន្តដំណើរការអភិវឌ្ឍក្រុមជំនុំ ដែលមានសុខភាពល្អ ដែលផ្ដល់ជូនដោយ អង្គការ Multiplication Network:

- ជំហានបន្ទាប់សម្រាប់ក្រុមជំនុំក្រោយពីបញ្ចប់វគ្គសិក្ខាសាលាស្ដីអំពីការពង្រឹងក្រុមជំនុំរបស់លោកអ្នក គឺត្រូវស្ទង់សិក្សាអំពីកត្តាជាក់លាក់ និងកិច្ចការនៃក្រុមជំនុំដែលមានសុខភាពល្អ ដែលត្រូវបានហៅថា «ពិនិត្យជីពចរក្រុមជំនុំរបស់លោកអ្នក»។ សូមមើលគេហទំព័ររបស់អង្គការ Multiplication Network ឬទាក់ទងមកកាន់តំណាងរបស់យើង សម្រាប់ព័ត៌មានអំពីការនេះ។
- ក្រុមជំនុំដែលបានចង់ចូលរួម ឬចាប់អារម្មណ៍នៅក្នុងការដាំក្រុមជំនុំ អាចចង់ចូលរួមនៅក្នុងកម្មវិធី «ក្រុមជំនុំកាន់តែច្រើន»។
- អធិស្ឋានបិទ។

**សេចក្ដីពិស្ដារសម្រាប់អ្នកធ្វើបទបង្ហាញ**

**ក្រុមជំនុំមូលដ្ឋាន** | នៅទំព័រនេះក្នុងសៀវភៅសិក្ខាកាម លោកអ្នកនឹងឃើញជំហានមូលដ្ឋានដែលត្រូវធ្វើតាម ប្រសិនបើគ្រូគង្វាល ឬអ្នកដឹកនាំចង់ឲ្យសិក្ខាសាលានេះមាននៅក្នុងក្រុមជំនុំមូលដ្ឋាន ឬនិកាយរបស់ខ្លួន។ លោកអ្នកក៏អាចរកបានសេចក្តីពិស្ដារផងដែរ អំពីរបាយការណ៍ ដែលត្រូវធ្វើទៅអង្គការ Multiplication Network នៅពេលក្រោយ។

សូមរកមើលមនុស្សដែលមានសមត្ថភាពដឹកនាំសិក្ខាសាលានេះ នៅពេលអនាគត។ វាជាការសំខាន់ណាស់សម្រាប់ឲ្យអ្នកដឹកនាំ រិះរកមធ្យោបាយដើម្បីពហុគុណក្រុមរបស់ខ្លួន ក្នុងការធ្វើបទបង្ហាញ ជាមួយគ្រូដែលមានគុណភាពខ្ពស់ សម្រាប់សិក្ខាសាលានៅពេលអនាគត។

**ការវាយតម្លៃ** | សិក្ខាសាលានីមួយៗ ត្រូវបញ្ចប់ដោយឲ្យសិក្ខាកាមបំពេញក្រដាសវាយតម្លៃ។ ក្រោយពីពិនិត្យមតិយោបល់របស់សិក្ខាកាមរួចហើយ សូមផ្ញើក្រដាសទាំងនោះ (ឬបទសង្ខេបនៃចម្លើយទាំងនោះ) មកកាន់តំណាងរបស់អង្គការ Multiplication Network ដែលនៅក្បែរលោកអ្នកបំផុត ឬបំពេញរបាយការណ៍នៅលើគេហទំព័រ www.multiplicationnetwork.org ។

**វិញ្ញាបនប័ត្រ** | សិក្ខាសាលាជាច្រើនបញ្ចប់ដោយការប្រគល់វិញ្ញាបនប័ត្រសម្រាប់ការចូលរួម។ ប្រសិនបើលោកអ្នកចូលចិត្ត លោកអ្នកអាចថតចម្លងវិញ្ញាបនប័ត្រនេះ ឬធ្វើវិញ្ញាបនប័ត្រប្រហាក់ប្រហែល ដោយប្រើរូបឡូហ្គោក្រុមជំនុំដែលបានឧបត្ថម្ភសិក្ខាសាលារបស់លោកអ្នក។

## សេចក្ដីបញ្ចប់សិក្ខាសាលា

ក្រុមជំនុំដែលធ្វើឲ្យមានការផ្លាស់ប្រែ:

១. ធ្វើតាមមហាបេសកកម្ម (ម៉ាថាយ ២២:៣៧)

- ស្រឡាញ់ព្រះអម្ចាស់អស់ពីចិត្ត
- ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង

២. សម្រេចមហាបេសកកម្ម (ម៉ាថាយ ២៨:១៨-២០)

- ចេញទៅបង្កើតសិស្ស
- ជ្រមុជទឹកឲ្យគេ
- បង្រៀនគេឲ្យកាន់តាម គ្រប់ទាំងសេចក្ដីដែលព្រះយេស៊ូបានបង្រៀន

ក្រុមជំនុំទាំងអស់ សុទ្ធតែត្រូវបានត្រាស់ហៅឲ្យចេះស្រឡាញ់ព្រះ ស្រឡាញ់អ្នកឯទៀតនៅក្នុងគ្រួសាររបស់ព្រះ និងស្រឡាញ់អស់អ្នកដែលត្រូវការស្គាល់ព្រះ។ ក្រុមជំនុំដែលធ្វើឲ្យមានការផ្លាស់ប្រែយល់ថា បេសកកម្មគ្រប់ជ្រុងជ្រោយ ជាគោលបំណងរបស់ខ្លួន ហើយផ្ដល់ការថែទាំដល់ពួកអ្នកដែលបានប្រែចិត្តជឿ។

ក្រុមជំនុំដែលលូតលាស់លឿនបំផុតនៅក្នុងពិភពលោកបានឯកភាពនឹងពាក្យនេះ:

***«ការប្ដូរផ្ដាច់មួយយ៉ាងធំ ចំពោះ បទបញ្ជាដ៏ធំ និង បេសកកម្មដ៏ធំ បង្កើតបានជាក្រុមជំនុំមួយធំ»***

*"A GREAT COMMITMENT to the GREAT COMMANDMENT and the GREAT COMMISSION makes a GREAT CHURCH."*

# សេចក្តីបន្ថែម | គ្រឹះខាងទេវសាស្ត្រ

លោកស្ទួត មើរី (Stuart Murry) សង្ខេបមូលដ្ឋានទេវសាស្ត្រនៅក្នុងសៀវភៅរបស់គាត់ ដែលមានចំណងជើង «ការចាក់គ្រឹះ» ថា ទាំងការលូតលាស់របស់ក្រុមជំនុំ ទាំងការដាំក្រុមជំនុំថ្មី មានមូលដ្ឋានរបស់ខ្លួនយ៉ាងហោចណាស់ក្នុងគោលការណ៍បីៈ

## ១. ការចាប់កំណើត

ព្រះជាម្ចាស់យកកំណើតក្នុងព្រះយេស៊ូ ដើម្បីដាក់អង្គទ្រង់ជាមួយមនុស្សជាតិ ហើយក្រុមជំនុំក៏ដូចគ្នា គឺចាប់កំណើតនៅក្នុងសហគមន៍មួយ ដែលមានសេចក្តីត្រូវការ ហើយនាំយករាជសារនៃដំណឹងល្អទាំងមូលទៅដល់សហគមន៍នោះ។ ក្រុមជំនុំជារូបកាយរបស់ព្រះគ្រិស្ត ស្ថិតនៅកន្លែងមួយពិតប្រាកដ ដោយដាក់ខ្លួនជាមួយប្រជាជន ដើម្បីឈោងចាប់ពួកគេដោយដំណឹងល្អអំពីជីវិតនៅក្នុងព្រះគ្រិស្ត។

**ខគម្ពីរគន្លឹះ** | ភីលីព ២:៥-៨
យ៉ូហាន ១:១, ១:១៤

*«ពាសពេញក្នុងប្រវត្តិសាស្ត្រ មានមនុស្សច្រើនណាស់ដែលចង់បានដូចជាព្រះ ប៉ុន្តែ មានតែព្រះមួយអង្គគត់ ដែលបានត្រឡប់ជាមនុស្ស»។*

## ២. ព្រះរាជបេសកកម្ម (បេសកកម្មរបស់ព្រះ)

ព្រះនៃព្រះគម្ពីរ ជាព្រះដែលជានិច្ចកាលស្វែងរកអ្នកបាត់បង់ និងអ្នកដែលមានសេចក្តីត្រូវការ ដើម្បីនាំពួកគេមកកាន់សេចក្តីសង្គ្រោះ និងការផ្លាស់ប្រែ។ តាមរបៀបដូចគ្នានេះ ក្រុមជំនុំត្រូវដើរតាមព្រះជាម្ចាស់ នៅក្នុងបេសកកម្មរបស់ខ្លួន ដើម្បីបង្កើតសិស្ស បំផ្លាស់បំប្រែសហគមន៍ និងធ្វើជាភ្នាក់ងារមួយនៃការផ្លាស់ប្រែ ជួសមុខព្រះជាម្ចាស់ និងរួមជាមួយព្រះជាម្ចាស់ នៅក្នុងសកម្មភាពទាំងឡាយរបស់ព្រះអង្គ ធ្វើសកម្មភាពក្នុងពិភពលោកនេះ។

**ខគម្ពីរគន្លឹះ** | យ៉ូហាន ៣:១៦, ម៉ាថាយ ២៨:១៨-២០,
ម៉ាកុស ១៦:១៥-១៦, លូកា ២៤:៤៦-៤៩

*«ក្រុមជំនុំកើតដោយសារបេសកកម្ម ដូចជាភ្លើងកើតដោយសារការបង្កាត់»។*
*ដោយ អ៊ីមែល ប្រាននែរ*

## ៣. ព្រះរាជរបស់ព្រះជាម្ចាស់

ក្រុមជំនុំប្រកាស ហើយចង្អុលបង្ហាញអំពីអ្វីដែលព្រះយេស៊ូបានប្រកាស និងចង្អុលបង្ហាញ ហើយនោះគឺ ការមកដល់នៃព្រះរាជ្យរបស់ព្រះ! ក្រុមជំនុំចង្អុលបង្ហាញ ផ្តល់សញ្ញា យកកំណើត ហើយបង្រៀនអំពីសេចក្តីល្អរបស់ព្រះ ការគ្រប់គ្រងរបស់ព្រះលើអ្វីៗសព្វសារពើ ដែលជាស្នាព្រះហស្តរបស់ព្រះអង្គ។

**ខគម្ពីរគន្លឹះ** | ១ពេត្រុស ២:៩-១២
កូឡូស ១:១៣

*«ចូរស្វែងរកនគរព្រះ និងសេចក្តីសុចរិតរបស់ព្រះអង្គជាមុន នោះទើបអ្វីៗទាំងអស់នឹងបានបន្ថែមមកអ្នក»* ដោយព្រះយេស៊ូវ (ម៉ាថាយ ៦:៣៣)

កំណត់ត្រា ៖

# បែបបទវាយតម្លៃ

១. តើលោកអ្នកវាយតម្លៃដូចម្តេច ចំពោះវគ្គសិក្ខាសាលាស្តីអំពីការដាំក្រុមជំនុំដែលមានសុខភាពល្អនេះ?

☐ ឥតខ្ចោះ ☐ ល្អណាស់ ☐ ល្អ ☐ មធ្យម ☐ អន់

២. តើលោកអ្នកណែនាំវគ្គសិក្ខាសាលានេះដល់អ្នកផ្សេងទៀតឬទេ?

☐ បាទ/ចាំ ☐ ប្រហែល ☐ ទំនងជាទេ ☐ ទេ

៣. តើអ្វីដែលលោកអ្នកចង់បន្ថែមដល់វគ្គសិក្ខាសាលានេះ?

________________________________________

________________________________________

________________________________________

៤. តើអ្វីដែលលោកអ្នកចង់ដកចេញពីវគ្គសិក្ខាសាលានេះ?

________________________________________

________________________________________

________________________________________

៥. តើលោកអ្នកឲ្យពិន្ទុវគ្គសិក្ខាសាលានេះដូចម្តេច?

☐ ឥតខ្ចោះ ☐ ល្អណាស់ ☐ ល្អ ☐ មធ្យម ☐ ខ្សោយ

៦. តើដ្យាក្រាម/ស្លាយបញ្ចាំងជួយលោកអ្នកឲ្យយល់មេរៀនទាំងនេះឬទេ?

☐ ជួយខ្លាំង ☐ ជួយខ្លះ ☐ មិនសូវ ☐ មិនជួយទេ

៧. គូសរង្វង់លើលេខដែលចង្អុលបង្ហាញអំពីគំនិតលោកអ្នកអំពីមេរៀនទាំងនោះ

| | តម្លៃខ្ពស់ | | | | តម្លៃទាប |
|---|---|---|---|---|---|
| មេរៀនទី១ \| ចិត្តឆេះឆួល និមិត្ត បេសកកម្ម | 5 | 4 | 3 | 2 | 1 |
| មេរៀនទី២ \| កត្តាទាំងប្រាំនៃក្រុមជំនុំដែលមានសុខភាពល្អ | 5 | 4 | 3 | 2 | 1 |
| មេរៀនទី៣ \| កិច្ចការទាំងប្រាំនៃក្រុមជំនុំដែលមានសុខភាពល្អ | 5 | 4 | 3 | 2 | 1 |
| មេរៀនទី៤ \| ប្រព័ន្ធ ផ្លាស់ ប្រែ | 5 | 4 | 3 | 2 | 1 |

៨. មតិ និងយោបល់បន្ថែមផ្សេងៗ

________________________________________

________________________________________

________________________________________

________________________________________

## សិក្ខាសាលាពេលខាងមុខ

ប្រសិនបើលោកអ្នកជាគ្រូគង្វាល ឬជាអ្នកដឹកនាំគ្រិស្តបរិស័ទ ហើយចង់ធ្វើសិក្ខាសាលានៅតាមក្រុមជំនុំមូលដ្ឋានរបស់លោកអ្នក ឬចូលរួមក្នុងនាមជាគ្រូហ្វឹកហ្វឺនសិក្ខាសាលា លោកអ្នកអាចធ្វើដូចខាងក្រោម៖

១. រៀបចំ និងដឹកនាំវគ្គសិក្ខាសាលា ស្តីអំពីការលូលាស់របស់ក្រុមជំនុំទាំងមូល ដោយប្រើសៀវភៅមេរៀនសម្រាប់អ្នកដឹកនាំ និងសៀវភៅមេរៀនសម្រាប់សិក្ខាកាម លោកអ្នកអាចរកបានដោយឥតគិតថ្លៃ នៅក្នុងគេហទំព័រ www.multiplicationnetwork.org

២. ទំនាក់ទំនងតំណាងរបស់អង្គការ Multiplication Network ហើយសុំឲ្យគាត់ជួយលោកអ្នកដឹកនាំវគ្គហ្វឹកហ្វឺនក្នុងក្រុមជំនុំ ឬក្នុងក្រុមរបស់លោកអ្នក។

៣. ក្រោយពីបញ្ចប់វគ្គសិក្ខាសាលារបស់លោកអ្នក សូមផ្ញើរបាយការណ៍ និងរូបថតក្រុមដែលលោកអ្នកបានហ្វឹកហ្វឺន មកកាន់យើងខ្ញុំ។ សូមផ្ញើសេចក្តីសង្ខេបអំពីការវាយតម្លៃ មកកាន់យើងខ្ញុំមកជាមួយផង។ គម្រោងរាយការណ៍ អាចរកបានយ៉ាងងាយស្រួលនៅលើគេហទំព័ររបស់យើង ឬលោកអ្នកអាចផ្ញើមកយើងខ្ញុំយ៉ាងសាមញ្ញ តាមព័ត៌មានខាងក្រោម៖

- របាយការណ៍សាមញ្ញអំពីវគ្គហ្វឹកហ្វឺន
- សិក្ខាសាលាស្តីអំពី «ការដាំក្រុមជំនុំដែលមានសុខភាពល្អ»
- កាលបរិច្ឆេទ
- ឈ្មោះក្រុមជំនុំ
- អាសយដ្ឋានក្រុមជំនុំ
- ឈ្មោះគ្រូគង្វាល
- ឈ្មោះអ្នកដែលបានដឹកនាំវគ្គហ្វឹកហ្វឺន
- ចំនួនសិក្ខាកាម
- មតិ ឬទីបន្ទាល់ខ្លីៗ
- សេចក្តីសង្ខេបអំពីការវាយតម្លៃ

ជានិច្ចកាល យើងតែងស្វែងរកគ្រូហ្វឹកហ្វឺនថ្មីៗ ដើម្បីពហុគុណព័ន្ធកិច្ចនេះ!

ប្រសិនបើលោកអ្នកមានអារម្មណ៍ថា ព្រះជាម្ចាស់អាចប្រើលោកអ្នកតាមរបៀបនេះ សូមទំនាក់ទំនងមកយើងខ្ញុំ តាមគេហទំព័រ www.multiplicationnetwork.org

multiplication network

*more churches, stronger churches*

# *Certificate of Recognition*

For having satisfactorily completed the workshop

## PLANTING HEALTHY CHURCHES

Sponsored by

Presented to: ______________________________

Place: ______________ Date: ______________

*Training Leaders for Church Growth and Church Planting*

www.multiplicationnetwork.org